សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université royale de droit et des sciences économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិរបស់សហជីពនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ កញ្ញា **នួន រាជនី**

ណែនាំដោយ
បណ្ឌិត **ស្រៀង ស៊ីម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université royale de droit et des sciences économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិរបស់សហជីពនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ កញ្ញា **នួន រាជនី**

ណែនាំដោយ
បណ្ឌិត **ស្រៀង ស៊ីម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ នួន រាជនី ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំសូមធ្វើការគោរពថ្លែងអំណរគុណចំពោះអ្នកមានគុណទាំងអស់ ដែលជាចំណែកមួយយ៉ាងធំធេងក្នុងការជួយជ្រោមជ្រែងរហូតដល់សមិទ្ធផលមួយនេះលេចចេញជារូបរាងឡើងដោយជោគជ័យ។

សូមគោរពថ្លែងអំណរគុណនិង សូមសម្តែងនូវការដឹងគុណកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ជូនចំពោះ **អ្នកមានគុណទាំងពីរ** ដែលលោក បានជួយជំរុញលើកទឹកចិត្ត និងផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ និងផ្នែកស្មារតី។ លោកទាំងពីរបានលះបង់កម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ ចិញ្ចឹមបីបាច់ ប្រៀនប្រដៅអប់រំកូន និងផ្តល់ឱកាសឱ្យកូនអាចទទួលបាននូវការអប់រំយ៉ាងជ្រៅជ្រះរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

ស្របពេលជាមួយគ្នានេះដែរ នាងខ្ញុំសូមអរគុណដល់ ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ដែលបានផ្តល់ទីកន្លែងឱ្យពួកយើងបានសិក្សារៀនសូត្រ ក៏ដូចជា សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូអ្នកគ្រូជាសាស្ត្រាចារ្យនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលអស់លោកតែងតែខិតខំប្រឹងប្រែងដោយមិន នឿយណាយក្នុងការផ្ទេរពុទ្ធិ និងបទពិសោធន៍ ទាំងឡាយទាក់ទងនឹង វិស័យច្បាប់ដល់នាងខ្ញុំ។ ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះអ្នកគ្រូបណ្ឌិត **ស្រៀង ស៊ីម** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះឡើង ដោយអ្នកគ្រូបានខិតខំ ចំណាយពេលវេលាដ៏មានតម្លៃ ធ្វើការណែនាំ ពន្យល់បង្ហាញពីចំណុចសំខាន់ៗ បង្ហាញពីរបៀបសរសេរ និងផ្តល់មតិយោបល់ល្អៗ ក៏ដូចជាឯកសារដែលពាក់ព័ន្ធនឹង ប្រធានបទស្រាវជ្រាវព្រមទាំងជួយពិនិត្យកែតម្រូវលើចំណុចខ្វះខាតទាំងឡាយ និងបានផ្តល់នូវអនុសាសន៍ល្អៗជាច្រើនអនេកសម្រាប់ស្នាដៃ នៃសារណានេះរហូតនាងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

ទន្ទឹមនឹងនេះផងដែរ នាងខ្ញុំក៏សូមអរគុណដល់ មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន (CJL) ដែលបាន បណ្តុះបណ្តាលទាំងចំណេះដឹងផ្នែកច្បាប់ និងជំនាញភាសាជប៉ុនរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ សូមគោរពដឹងគុណ យ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យនៃមជ្ឈមណ្ឌល ដែលលោកបានបណ្តុះបណ្តាលឱ្យនាងខ្ញុំទទួលបានចំណេះដឹងយ៉ាងស៊ីជម្រៅលើប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ទើបអាចឱ្យការសិក្សាច្បាប់ប្រទេសកម្ពុជា កាន់តែមានប្រសិទ្ធិភាព។

ជាចុងក្រោយនាងខ្ញុំសូមគោរពជូនពរ ដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូអ្នកគ្រូជាសាស្ត្រចារ្យ មិត្តអ្នកអានទាំងអស់ និងជាពិសេសអ្នកគ្រូបណ្ឌិត **ស្រៀង ស៊ីម** សូមឱ្យជួបប្រទះ នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមគោរពលោកសាស្ត្រាចារ្យ និងសូមស្វាគមន៍មិត្តៗនិស្សិត អ្នកអាន អ្នកស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់លើឯកសារ និងការស្រាវជ្រាវផ្សេងៗជាទីរាប់អាន សារណាបញ្ចប់ការសិក្សាស្តីពីប្រធានបទ **“សិទ្ធិរបស់សហជីពនៅកម្ពុជា”** ដែលបានចាប់កំណើតឡើង និងកំពុងមានវត្តមាននៅចំពោះវង់ភ័ក្រអ្នកអាននេះ គឺជាកិច្ចការស្រាវជ្រាវថ្មីមួយ ក្រោមការខិតខំប្រឹងប្រែងរបស់នាងខ្ញុំ។

ក្នុងកិច្ចការស្រាវជ្រាវនេះ នាងខ្ញុំក៏បានជួបនូវបញ្ហាមួយចំនួនក្នុងការស្វែងរកនូវប្រភពឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ ជាពិសេសឯកសារទិន្នន័យ ស្ថិតិនាពេលបច្ចុប្បន្ន។ បើទោះបីយ៉ាងណា នាងខ្ញុំនៅតែខិតខំប្រឹងប្រែងរៀបរៀងនូវកិច្ចការស្រាវជ្រាវមួយនេះទៅតាមលទ្ធភាពដែលនាងខ្ញុំធ្លាប់បានសិក្សាស្វែងយល់កន្លងមក ការប្រឹក្សាជាមួយអ្នកគ្រូណែនាំ និងតាមឯកសារពិគ្រោះយោបល់នានាដែលអាចស្វែងរកនៅបណ្ណាល័យ ឬតាមរយៈគេហទំព័រនានា។ ទោះបីជាបានស្រាវជ្រាវនិងវិភាគទៅលើឯកសារជាច្រើនក៏ដោយក្តី មិនមែនមានន័យថាខ្លឹមសារនៃកិច្ចការនេះមានភាពគ្រប់ជ្រុងជ្រោយ ស៊ីជម្រៅ ឬការបកស្រាយមានភាពច្បាស់លាស់ ឬលម្អិតអ្វីពេកនោះទេ ដោយសារតែនេះជាប្រធានបទមួយដែលពុំសូវមានអ្នកស្រាវជ្រាវទេ និងសូម្បីតែនាងខ្ញុំក៏ពុំធ្លាប់បានសិក្សាស្រាវជ្រាវពីមុនមកផងដែរ និងម្យ៉ាងទៀតដោយហេតុថាឯកសារដែលពាក់ព័ន្ធមិនសូវមានផងដែរ។ នាងខ្ញុំសង្ឃឹមថា កិច្ចការដែលនាងខ្ញុំបានចងក្រងនេះអាចជាចំណែកមូលដ្ឋានមួយ ឬជាឯកសារជំនួយស្មារតីបន្ថែមសម្រាប់យកទៅធ្វើការស្រាវជ្រាវបន្តពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ។

ជាចុងក្រោយ នាងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់អ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា ពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ អក្ខរាវិរុទ្ធ ដើម្បីជួយកែលម្អឱ្យកិច្ចការស្រាវជ្រាវមួយនេះកាន់តែល្អ និងមានខ្លឹមសារល្អ។

ជាទីបញ្ចប់ នាងខ្ញុំសូមជូនពរដល់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ អ្នកអាន និងមិត្តនិស្សិតទាំងអស់ ទទួលបានពរទាំងឡាយបួនប្រការ និងមានសេក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យលើគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃសហជីពក្នុងប្រទេសកម្ពុជា**

**១.១.សញ្ញាណទូទៅនៃសហជីព** ............................................................ ៤

១.១.១.និយមន័យ ............................................................ ៤

១.១.២.រចនាសម្ព័ន្ធសហជីព ............................................................ ៥

១.១.៣.សិទ្ធិក្នុងការបង្កើត និង ចូលជាសមាជិក ............................................................ ៧

**១.២.ប្រវត្តិ និង ការវិវត្តនៃសហជីពនៅកម្ពុជា** ............................................................ ១៣

១.២.១.ស្ថានភាពការអនុវត្តសិទ្ធិសហជីពមុនមានច្បាប់ការងារ ឆ្នាំ១៩៩៧ ............................................................ ១៣

១.២.២.ស្ថានភាពការអនុវត្តសិទ្ធិសហជីពចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១៦ ............................................................ ១៤

១.២.៣.ស្ថានភាពការអនុវត្តសិទ្ធិសហជីពចាប់ពីឆ្នាំ២០១៦ ............................................................ ១៥

**ជំពូកទី២**

**សិទ្ធិរបស់សហជីព និងភាពជាតំណាងបំផុតនៅកម្ពុជា**

**២.១.សិទ្ធិរបស់សហជីព** ............................................................ ១៧

២.១.១.សិទ្ធិក្នុងការតំណាង ............................................................ ១៧

២.១.២.សិទ្ធិទទួលបានបញ្ជិកា ............................................................ ១៧

២.១.៣.សិទ្ធិក្នុងការចងសម្ព័ន្ធភាព ............................................................ ១៨

២.១.៤.សិទ្ធិក្នុងការប្រមូលវិភាគទាន ............................................................ ១៨

២.១.៥.សិទ្ធិទទួលបានការការពារពិសេស ............................................................ ១៩

**២.២.ភាពជាតំណាងបំផុតនៃសហជីព** ............................................................ ២០

២.២.១.ប្រភេទនៃភាពជាតំណាងបំផុត ............................................................ ២០

២.២.២.ការបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុត ............................................................ ២១

២.២.៣.ការស្នើសុំទទួលស្គាល់ភាពជាតំណាងបំផុតនៃសហជីព ............................................................ ២២

២.២.៤.អានុភាពនៃសេចក្តីបញ្ជាក់ភាពជាតំណាងបំផុតនៃសហជីព ...... ២៤
២.២.៥.សិទ្ធិ និងករណីយកិច្ចរបស់សហជីពដែលមានភាពជាតំណាងបំផុត ...... ២៤
២.២.៦.សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិច ...... ២៥
២.២.៧.អនុសញ្ញារួម និងការដោះស្រាយវិវាទការងាររួម ...... ២៦

**ជំពូកទី៣**

**បញ្ហាប្រឈមនិងដំណោះស្រាយជុំវិញការអនុវត្តសិទ្ធិសហជីពនៅកម្ពុជា**

**៣.១.បញ្ហាប្រឈមរបស់សហជីពកម្ពុជា** ...... ២៩
៣.១.១. ការអនុវត្តច្បាប់ស្តីពីសហជីព ...... ២៩
៣.១.២.ការខ្វះខាតនៃការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សហជីពក្នុងនាមជាអ្នកតំណាង ...... ៣២
**៣.២.ដំណោះស្រាយ** ...... ៣៤
៣.២.១.ចំពោះការកំណត់ចំនួនសមាជិកក្នុងការបង្កើតសហជីព និង នីតិវិធីក្នុងការចុះបញ្ជី ...... ៣៤
៣.២.២.លើកកម្ពស់យន្តការពិគ្រោះយោបល់ និងការអប់រំច្បាប់ ...... ៣៥
**សេចក្តីសន្និដ្ឋាន** ...... ៣៧
**អនុសាសន៍** ...... ៣៩
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាទូទៅស្ថានភាពការងារនៅក្នុងប្រទេសនីមួយៗគឺអាស្រ័យទៅលើសេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសនោះ ដូចនេះ ប្រសិនបើប្រទេសមួយមានសេដ្ឋកិច្ច និងនយោបាយល្អ នោះប្រព័ន្ធការងារក៏ល្អផងដែរ។ ជាឧទាហរណ៍ ការរីកចម្រើននៃប្រព័ន្ធការងារត្រូវបានជំរុញដោយការនាំចេញនូវ ផលិតផលកសិកម្ម និងសិប្បកម្ម របស់អាមេរិក ឬចិនជាអាទិ៍ ទៅកាន់ប្រទេសដទៃផ្សេងទៀតដែលជាកម្លាំងចលករជំរុញឱ្យ ពលរដ្ឋរបស់ប្រទេសនោះទទួលបាននូវប្រព័ន្ធការងារល្អមួយ។ តែបើយើងក្រឡេក មកមើលពីស្ថានភាព របស់ប្រទេសកម្ពុជាវិញនោះ កម្ពុជាគឺជាប្រទេសដែលទើបតែបានងើបឡើងវិញពីសង្គ្រាម និងទទួលបានសន្តិភាព ក៏ដូចជាស្ថិរភាពនយោបាយនៅទសវត្សឆ្នាំ១៩៩០នេះទេ ហើយការទទួលបាននូវសន្តិភាពនេះហើយ ទើបធ្វើឱ្យកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់មួយក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងនយោបាយរបស់ខ្លួន ដែលជាហេតុធ្វើឱ្យប៉ុន្មានឆ្នាំក្រោយមកនេះ ការជំរុញផ្នែកសេដ្ឋកិច្ចបានក្លាយជាគ្រឹះដ៏សំខាន់សម្រាប់ប្រទេស ដូចជា វិស័យកាត់ដេរ វាយនភណ្ឌ វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យសំណង់ និងផលិតកម្មជាអាទិ៍ ហើយក្នុងចំណោមវិស័យទាំងនេះមានតែ វិស័យកាត់ដេរ វាយនភណ្ឌ ប៉ុណ្ណោះដែលមានកម្មករនិយោជិតច្រើនជាងគេ ព្រោះថាការងារក្នុងវិស័យកាត់ដេរ វាយនភណ្ឌនេះ មិនកំណត់ពីកម្រិតនៃការយល់ដឹងទេ។ អាស្រ័យហេតុនេះហើយ ទើបគេសង្កេតឃើញថា អត្រានៃសិស្សដែលបោះបង់ការសិក្សាត្រឹមថ្នាក់មធ្យមសិក្សាបឋមភូមិ (គិតត្រឹមថ្នាក់ទី៩) ដើម្បីប្រកបរបរចិញ្ចឹមជីវិត គឺនៅមានចំនួនច្រើននៅឡើយ។[១] កម្មករនិយោជិតភាគច្រើន ជ្រើសរើសការធ្វើការងារដែលនរណាក៏អាចធ្វើបាន និងមិនគិតពីចំណេះដឹងរបស់ពួកគេ។ ឧទាហរណ៍ ការធ្វើការជាកម្មករនិយោជិតនៅរោងចក្រ សហគ្រាស ជាអាទិ៍។ ដោយសារតែនៅតាមរោងចក្រ សហគ្រាស គឺជាការងារ ដែលមនុស្សគ្រប់រូបអាចធ្វើបាន ដូច្នេះហើយទើបកម្មករច្រើននៅតែខិតខំប្រឹងប្រែងធ្វើការងាររបស់ខ្លួន ដើម្បីចិញ្ចឹមជីវិត បើទោះបីជាសិទ្ធិ និងផលប្រយោជន៍របស់ពួកគេត្រូវបាន បំពានពីសំណាក់និយោជកយ៉ាងណាក៏ដោយ។

ដោយការឃើញពីភាពលំបាក និង ដើម្បីការពារដល់កម្មករនិយោជិតដែលជាក្រុមមនុស្សដ៏សំខាន់មួយនៅក្នុងសង្គមកម្ពុជា ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ៨៧ (ឆ្នាំ១៩៥០)ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម និង អនុសញ្ញាលេខ៩៨ (ឆ្នាំ១៩៥១) ស្តីពីការអនុវត្តគោលការណ៍

[១] របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភាឆ្នាំ២០១៨~២០២២ , (មិនា ២០២៣) https://pressocm.gov.kh/wp-content/uploads/២០២៣/០៦/Brief-report-main-achievements-of-the-implementation-of-the-Rectangular-Strategy-Phase-៤.pdf(បានចូលមើលចុងក្រោយ ២៤ មិថុនា ២០២៤)។

នៃសិទ្ធិបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព របស់អង្គការ ILO ក្នុងឆ្នាំ ១៩៩៧។ ដោយសារតែមានការគាំទ្រ និងការពារពីច្បាប់ជាតិ និងអន្តរជាតិបែបនេះហើយ ទើបកម្មករនិយោជិតជាច្រើនបានប្រមូលផ្តុំគ្នានៅក្រោមអង្គការវិជ្ជាជីវៈពិសេសមួយហៅថា "សហជីព" ដើម្បីឱ្យសំឡេង និងមតិយោបល់របស់ពួកគេត្រូវបានដឹងឮជាសាធារណៈ ដែលសិទ្ធិនេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញមាត្រា៣៦(កថាខណ្ឌ៥-៦)។[២] មកទល់បច្ចុប្បន្នសហជីពនៅប្រទេសកម្ពុជា មានវត្តមានចំនួន៦២៧២ (គិតត្រឹមឆ្នាំ២០២៣) ក៏ប៉ុន្តែចំនួននេះ ជាចំនួនតិចនៅឡើយ ប្រសិនបើប្រៀបធៀបជាមួយប្រទេសដទៃ ដូចជាប្រទេសជប៉ុនមានចំនួនសហជីព ដល់២២ ៧៨៩ (គិតត្រឹមឆ្នាំ២០២៣)[៣] និងប្រទេសវៀតណាមដែលមានចំនួនសហជីព ដល់ទៅ១២២ ០០០ (គិតត្រឹមឆ្នាំ២០២៣)។[៤] ទន្ទឹមនឹងនេះក៏មានការលើកឡើងពីសំណាក់សហជីពមួយចំនួនជុំវិញភាពតឹងរ៉ឹងនៃការចុះបញ្ជីសហជីពផងដែរ។[៥] តើនេះជាកត្តាតែមួយគត់ដែលធ្វើឱ្យសហជីពនៅកម្ពុជានៅតែមានចំនួនតិចទាំងដែលមានការគាំពារពីច្បាប់ជាតិ និងអន្តរជាតិមែនឬទេ? (ចំណុចនេះយើងនឹង លើកយកមកពិភាក្សានៅជំពូកទី៣ )

មិនតែប៉ុណ្ណោះ មូលដ្ឋាននៃច្បាប់ទាំងពីរក៏បានផ្តល់សិទ្ធិដល់កម្មករនិយោជិតគ្រប់រូប អាចក្លាយជាតំណាងក្នុងសហជីពផងដែរ ប្រសិនបើពួកគេបំពេញតាមតម្រូវការ និងមានការជ្រើសរើសដោយសំឡេងគាំទ្ររបស់កម្មករនិយោជិតនៃសហគ្រាសឬក្រុមហ៊ុននោះ។ មិនតែប៉ុណ្ណោះ សូម្បីតែជនបរទេសក៏មានសិទ្ធិអាចក្លាយជាតំណាងសហជីពបានដែរ ( មាត្រា ២៧០ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការងារ )។ ក៏ប៉ុន្តែកម្មករនិយោជិតមួយចំនួន (ជាពិសេសកម្មករនិយោជិត នៅតាមសហគ្រាស ឬរោងចក្រ) ខ្លះបានបញ្ចប់ការសិក្សាត្រឹមថ្នាក់មធ្យមសិក្សា ហើយខ្លះទៀត ពុំមានចំណេះដឹងមូលដ្ឋានភាសាខ្មែរទាល់តែសោះ បែបនេះតើពួកគេអាចការពារនូវសិទ្ធិនិងផលប្រយោជន៍របស់កម្មករបានពេញលេញដែរឬទេ? ព្រោះថាចំណុចមួយចំនួន នៃតួនាទីមួយចំនួន

---

[២]ការវិភាគផ្នែកសិទ្ធិមនុស្ស នៃសេចក្តីព្រាងច្បាប់ស្តីពីសហជីព" រៀបចំឡើងដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស ប្រចាំកម្ពុជា
https://cambodia.ohchr.org/sites/default/files/TUL_Analysis-Kh.pdf (បានចូលមើលចុងក្រោយ ២៤ មិថុនា ២០២៤)។

[៣] ទិដ្ឋភាពទូទៅនៃការស្ទង់មតិមូលដ្ឋានសហជីពការងារឆ្នាំ ២០២៣ របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពជប៉ុន
厚生労働省「令和 ៥ 年労働組合基礎調査の概況」៣ 頁
https://www.mhlw.go.jp/toukei/itiran/roudou/roushi/kiso/២៣/dl/gaikyou.pdf(បានចូលមើលចុងក្រោយ ២៨ មិថុនា ២០២៤)។

[៤] Japan International labor foundation , ឯកសារសរុបទិន្នន័យរបស់សហព័ន្ធការងារវៀតណាម(VGCL)
（公益財団法人国際労働財団、ベトナム労働総同盟の合計データのレポート(VGCL) ）
https://www.jilaf.or.jp/nc_view/nc_view-១៣៦១/

[៥] មេដឹកនាំសហជីព៖ ការបង្កើតសហជីពឯករាជ្យកំពុងស្ថិតក្រោមការរឹតត្បិត និងប្រឈមការរើសអើងកាន់តែខ្លាំង
https://khmer.voanews.com/a/union-leaders-say-after-the-amendment-of-labor-laws-the-formation-of-independent-unions-is-under-restriction-and-faces-discrimination/៧១៦០០៥១.html(បានចូលមើលចុងក្រោយ ២៤ មិថុនា ២០២៤)។

របស់សហជីព នៃច្បាប់ស្តីពីសហជីព គឺទាមទារឱ្យសហជីពទាំងអស់ យ៉ាងហោចណាស់មានចំណេះដឹង មូលដ្ឋានទាក់ទងនឹងច្បាប់ការងារផងដែរ ទើបអាចអនុវត្តតួនាទីឬភារកិច្ចទាំងនោះបាន។ (ចំណុចនេះយើងនឹងលើកយកមកពិភាក្សានៅជំពូកទី៣ )

តាមរយៈមូលដ្ឋានខាងលើនេះ យើងឃើញថា សិទ្ធិសហជីពមួយចំនួននៅតែជួបប្រទះនូវបញ្ហាប្រឈម និងមានវិវាទផ្សេងៗកើតឡើងជាបន្តបន្ទាប់ បើទោះបីជាច្បាប់ស្តីពីសហជីព បានចែងបង្កើតឡើងដើម្បីជំរុញឱ្យមានសុខដុមរមនា មានក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងធានានូវសិទ្ធិសេរីភាពក្នុងការចរចាជាសមូហភាពរវាងកម្មករនិយោជិត និងនិយោជកក៏ដោយក្តី។ ដូច្នេះហើយទើបមានចំណោទបញ្ហាចោទឡើងថា តើតំណាងសហជីពអាចបំពេញតួនាទី របស់ខ្លួនបានដែរឬទេបើច្បាប់មានលក្ខណៈតឹងរ៉ឹងយ៉ាងនេះ? ម្យ៉ាងទៀតដោយសារសហជីពមូលដ្ឋានត្រូវរើសចេញពីកម្មករនិយោជិត ហើយមួយចំនួនធំពុំមានចំណេះដឹងផ្នែកច្បាប់នោះទេ ពិសេសច្បាប់ការងារ។ បើបែបនេះតើគេអាច ការពារនូវសិទ្ធិរបស់កម្មករនិយោជិត ពិសេសកម្មករដែលប្រកបមុខរបរជាកម្មករនិយោជិត ធ្វើការងារដែលប្រើប្រាស់កម្លាំង បានដែរឬយ៉ាងណា?

ដូច្នេះហើយ ទើបនាងខ្ញុំមានគោលបំណងលើកយកប្រធានបទនេះឡើង ដើម្បីបង្ហាញពីភាពខ្វះខាតរបស់ច្បាប់ការងារ និងកែតម្រូវឱ្យប្រព័ន្ធការងារនៅកម្ពុជាកាន់តែរីកចម្រើន ដូចទៅនឹងប្រទេសជឿនលឿនដទៃទៀត។

ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ ក៏ដូចជាឆ្លើយតបនឹងបញ្ហាដែលបានលើកឡើងខាងលើ យើងនឹងធ្វើការសិក្សាចំនួន៣ជំពូកគឺ " ទិដ្ឋភាពទូទៅនៃសហជីពក្នុងប្រទេសកម្ពុជា " (ជំពូកទី១) " សិទ្ធិរបស់សហជីព និងភាពជាតំណាងបំផុតនៅកម្ពុជា " (ជំពូកទី២) និង " បញ្ហាប្រឈមនិងដំណោះស្រាយជុំវិញការអនុវត្តសិទ្ធិសហជីពនៅកម្ពុជា "(ជំពូកទី៣)។

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃសហជីព
# ក្នុងប្រទេសកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃសហជីពក្នុងប្រទេសកម្ពុជា

មុននឹងសិក្សាពីបញ្ហារបស់សហជីពនៅកម្ពុជា នៅក្នុងជំពូកទី១នេះ យើងនឹងសិក្សាពីសញ្ញាណទូទៅនៃសហជីព(១.១) និងដើមកំណើតនៃគោលគំនិតសហជីព ជាមួយនិងប្រវត្តិនៃការកកើតសហជីព (១.២) ជាមុនសិន។ ដើម្បីដឹងថាតើសហជីពជាអង្គការវិជ្ជាជីវៈបែបណា? ដើម្បីបង្កើតសហជីពមានលក្ខខណ្ឌបែបណាខ្លះ?

## ១.១.សញ្ញាណទូទៅនៃសហជីព

### ១.១.១.និយមន័យ

សហជីព គឺជាអង្គការវិជ្ជាជីវៈដែលសំដៅដល់ការរួបរួមគ្នា ដែលបង្កើតឡើងដោយកម្មករនិយោជិតជាក្រុម ជាពួកដោយការរួបរួមគ្នា និងដោយស្ម័គ្រចិត្ត សំដៅសហការគ្នាធ្វើសកម្មភាព ឬអភិវឌ្ឍនីតិក្រមផ្ទាល់ខ្លួនដើម្បីសម្រេចទិសដៅ ឬគោលបំណងជាក់លាក់នៃវិជ្ជាជីវៈ។[៦] តាមន័យនៃច្បាប់នេះ អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ត្រូវបានគេហៅថា «សហជីព»។[៧] និយាយឱ្យសាមញ្ញ សហជីពជាកម្លាំងចលករមួយដែលជាការរួបរួមគ្នា របស់កម្មករក្នុងការងារតែមួយដើម្បី បង្កើតសហជីពនៅកន្លែងធ្វើការរបស់ខ្លួន ដើម្បីឱ្យគាត់មានសិទ្ធិក៏ដូចជាអំណាចក្នុងការចចា ជជែកជាមួយនិយោជកក្នុងការកែប្រែលក្ខខណ្ឌការងារ ឬក៏សុខភាពសុវត្ថិភាពនៅកន្លែងធ្វើការ រួមទាំងប្រាក់ឈ្នួល ឬអត្ថប្រយោជន៍ផ្សេងៗ ម្យ៉ាងទៀតវាក៏ជាផ្នែកមួយដែលអាចនាំឱ្យ កម្មករនិយោជិតចេះតស៊ូមតិទាមទារភាពត្រឹមត្រូវ របស់ខ្លួនទៅតាមលក្ខខណ្ឌការងារពីភាគីនិយោជកទាមទារឱ្យមានការគោរពមកលើសិទ្ធិកម្មករនិយោជិត ស្របទៅតាមច្បាប់ស្តីពីការងារ ជាពិសេសនោះគឺស្របទៅតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។

ដោយហេតុនេះហើយទើបមានទស្សនៈមួយបានលើកឡើងថា " សហជីព គឺជាដៃគូមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិនិងការពារអត្ថប្រយោជន៍របស់កម្មករនិយោជិត ហើយតម្រូវឱ្យសហជីពទាំងអស់ត្រូវ ពង្រឹងគុណវុឌ្ឍិសមត្ថភាព ដើម្បីចូលរួមកសាងបរិយាកាសអាជីវកម្មមួយដែលមានភាពសុខដុមរមនា និងប្រកបដោយភាពទាក់ទាញ ក្នុងការរក្សាប្រយោជន៍ជូនដល់កម្មករនិយោជិតឱ្យបានយូរអង្វែង "។[៨]

---

[៦] ច្បាប់ស្តីពីសហជីព, លេខ នស/រកម/០៥១៦/០០៧, ១៧ ឧសភា ២០១៦, មាត្រា៤ ( ឬ ហៅថា ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦)។

[៧] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ មាត្រា៤។

[៨] ការលើកឡើងរបស់ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពិធីជួបសំណេះសំណាលការងារជាមួយសហភាព និងសហព័ន្ធសហជីពចំនួន២០៥នៅទូទាំងប្រទេស នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ https://www.information.gov.kh/articles/១១៥១៦៥(បានចូលមើលចុងក្រោយ ២៩ មិថុនា ២០២៤)។

ការបង្កើតសហជីព បានបម្រើឱ្យផលប្រយោជន៍របស់កម្មករនិយោជិត តាមរយៈការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការលើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសម្ភារជាសមូហភាព និងជាឯកត្តជនតាមការកំណត់ដោយលក្ខន្តិកៈផងដែរ។[៩]

ទន្ទឹមនេះ ដើម្បីឱ្យសហជីពបំពេញកិច្ចការជាប្រយោជន៍ដល់កម្មករនិយោជិតដោយស្របច្បាប់ តាមរយៈការទទួលបានសិទ្ធិ និងផលប្រយោជន៍តាមច្បាប់ គឺសហជីពត្រូវតែចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[១០]

### ១.១.២.រចនាសម្ព័ន្ធសហជីព

យោងទៅតាម បទដ្ឋានគតិយុត្តជាតិ និងច្បាប់អន្តរជាតិ មិនបានហាមឃាត់សិទ្ធិសេរីភាពរបស់សហជីព នៅក្នុងការចងក្រងគ្នាជាសម្ព័ន្ធនោះឡើយ។ កម្មករនិយោជិត មានសិទ្ធិបង្កើត ឬចូលរួមក្នុងសហព័ន្ធ ឬសម្ព័ន្ធសហជីព ហើយអង្គការសហព័ន្ធ ឬសម្ព័ន្ធសហជីពទាំងនេះ ក៏មានសិទ្ធិចងសម្ព័ន្ធជាមួយនិងអង្គការអន្តរជាតិនៃកម្មករនិយោជិតផងដែរ។[១១]

[៩] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៥។

[១០] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១១។

[១១] អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពនៃសមាគម និងការពារសិទ្ធិនៃការបង្កើតសមាគម, ៤ កក្កដា ១៩៥០, មាត្រា៥។

ប៉ុន្តែទោះជាយ៉ាងនេះក្តីការចងគ្នាជាសម្ព័ន្ធណាមួយ ឬការប្រមូលផ្តុំរបស់សហជីពទាំងនោះក៏ត្រូវស្រប ទៅតាមច្បាប់ផងដែរ។ នៅប្រទេសកម្ពុជា រចនាសម្ព័ន្ធសហជីព និងសម្ព័ន្ធភាពរវាងសហជីព ត្រូវបានបែងចែក ជា៣ថ្នាក់ មានដូចជា[១២]៖




- **សហជីពមូលដ្ឋាន (ថ្នាក់មូលដ្ឋាន)** ត្រូវបានបង្កើតឡើងដោយកម្មករនិយោជិតនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមូលដ្ឋាននោះចំនួនយ៉ាងតិច ១០ (ដប់) នាក់។ សហជីពមូលដ្ឋាន សំដៅដល់អង្គការ វិជ្ជាជីវៈដែលបង្កើតឡើងដោយកម្មករនិយោជិត ដោយការរួបរួមគ្នា និងដោយការស្ម័គ្រចិត្តនៅក្នុង មូលដ្ឋាននៃសហគ្រាស ឬគ្រឹះស្ថាននោះ។[១៣] ពោលគឺសហជីពមូលដ្ឋាន អាចចងក្រងគ្នាទៅ តាមទីតាំងប្រកបការងារ ឬនៅតាមទីកន្លែង ដែលកម្មករនិយោជិតនោះធ្វើការផ្ទាល់ ដោយតម្រូវឱ្យ មានសមាជិកគាំទ្រចាប់ពី១០នាក់ឡើងទៅ ទើបអាចបង្កើតសហជីពបាន។
- **សហព័ន្ធសហជីព (ថ្នាក់ដែលកើតចេញពីការប្រមូលផ្តុំរបស់សហជីពមូលដ្ឋាន)** ត្រូវបានបង្កើត ឡើងដោយសហជីពមូលដ្ឋានដែលមានបញ្ជិកា(សហជីពដែលបានចុះបញ្ជីរួច)ចំនួនយ៉ាងតិច ៧

[១២] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១០។
[១៣] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៤។

(ប្រាំពីរ)។ សហព័ន្ធសហជីព សំដៅដល់អង្គការវិជ្ជាជីវៈដែលត្រូវបានបង្កើតឡើងដោយការរួបរួមគ្នា និងដោយស្ម័គ្រចិត្តពីសំណាក់សហជីពមូលដ្ឋាន ដែលមានវិជ្ជាជីវៈដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលមានសកម្មភាពសេដ្ឋកិច្ចដូចគ្នា ឬប្រហាក់ប្រហែលគ្នាក្នុងតំបន់ឬទីភូមិសាស្ត្រតែមួយ។[14]

- **សហភាពសហជីព ឬសម្ព័ន្ធសហព័ន្ធសហជីព (ថ្នាក់ជាតិ)** ត្រូវបានបង្កើតឡើងដោយសហព័ន្ធសហជីពដែលមានបញ្ជិកា(សហជីពដែលបានចុះបញ្ជីរួច)ចំនួនយ៉ាងតិច ៥ (ប្រាំ)។ សហភាពសហជីព ឬសម្ព័ន្ធសហព័ន្ធសហជីព សំដៅដល់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ដែលបង្កើតឡើងដោយការរួបរួមគ្នា និងដោយស្ម័គ្រចិត្តពីសំណាក់សហព័ន្ធសហជីព។[15]

### ១.១.៣.សិទ្ធិក្នុងការបង្កើត និង ចូលជាសមាជិក

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។[16]

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រង់មាត្រា២៣ បានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន"។ ចំណែកក្នុងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មានចែងថា "ជនគ្រប់រូបមានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន"។ លើមូលដ្ឋាននេះ បញ្ញត្តិមាត្រា៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងកំណត់អំពីសិទ្ធិខាងសហជីពថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ហើយការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់"។

ដោយហេតុនេះហើយ ទើបមាត្រា៥ នៃច្បាប់ស្តីសហជីព ឆ្នាំ២០១៦ បានកំណត់ថា "ដោយគ្មានការប្រកាន់អ្វីទាំងអស់កម្មករនិយោជិត មានសិទ្ធិបង្កើតសហជីពតាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសម្រាប់តែការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការលើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសម្ភារជាសមូហភាព និងជាឯកត្តជនចំពោះបុគ្គលដែលលក្ខន្តិកៈរបស់សហជីព ឬសមាគមនិយោជកនោះបានកំណត់"។ ដោយផ្អែកលើលើមូលដ្ឋាននេះ កម្មករនិយោជិតមានសិទ្ធិដូចខាងក្រោមៈ

[14] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៤។
[15] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៤។
[16] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៣១។

- ចូលរួមបង្កើតសហជីព
- អាចជាសមាជិករបស់សហជីពហើយស្ថិតនៅក្រោមវិធានរបស់សហជីពនោះ
- អាចចូលរួមនៅក្នុងសកម្មភាពស្របច្បាប់របស់សហជីពដែលគាត់ជាសមាជិក
- អាចស្វះស្វែង និងទទួលបានមុខងារនៅក្នុងសហជីពណាមួយដែលខ្លួនជាសមាជិកហើយស្ថិតនៅក្រោមវិធានរបស់សហជីពនោះ
- អាចចូលរួមនៅក្នុងការបោះឆ្នោតជ្រើសរើសអ្នកតំណាងនៅកន្លែងការងារ នៅពេលដែលមានបទប្បញ្ញត្តិចែងអំពីការបោះឆ្នោតនេះ
- អាចត្រូវជ្រើសរើស ឬតែងតាំង និងធ្វើជាអ្នកតំណាងសម្រាប់កន្លែងការងារនៅពេលដែលមានបទប្បញ្ញត្តិចែងអំពីការជ្រើសរើស ឬតែងតាំងនេះ
- អាចអនុវត្តសិទ្ធិដទៃទៀតដែលផ្តល់ដោយច្បាប់នេះ។[១៧]

មិនតែប៉ុណ្ណោះកម្មករនិយោជិត ទាំងឡាយក៏អាចចូលជាសមាជិកសហជីពដោយសេរី ទៅតាមជម្រើសរបស់ខ្លួន ដោយគ្មានការរើសអើងអ្វីទាំងអស់ ហើយគ្មានបុគ្គលណាមួយ រួមទាំងសហជីពមិនអាចរារាំងដល់សិទ្ធិនោះទេ ប៉ុន្តែនៅក្នុងសហជីពមិនអាចមានសមាជិកជានិយោជកឡើយ។[១៨]

ទន្ទឹមនឹងនេះដែរ កម្មករនិយោជិតក៏មានសិទ្ធិក្នុងការមិនចូលរួមនៅក្នុងសហជីព និងអាចធ្វើការដកខ្លួនពីសហជីពដែលខ្លួនបានចូលរួមនោះបានគ្រប់ពេលវេលា។[១៩]

លើសពីនេះទៅទៀត ច្បាប់ស្តីពីសហជីពអនុញ្ញាតឱ្យសមាជិក នៃសហជីព អាចចូលរួមក្នុងការដឹកនាំការងារគ្រប់គ្រង និងការងាររដ្ឋបាលរបស់សហជីពស្របទៅតាមការកំណត់នៅក្នុងលក្ខន្តិកៈនីមួយៗរបស់សហជីព ប្រសិនបើបុគ្គលនោះ បានបំពេញលក្ខខណ្ឌដោយអនុលោមតាមបញ្ញត្តិ ដែលមានចែងក្នុងមាត្រា២១ នៃច្បាប់ស្តីពីសហជីព។ លក្ខន្តិកៈសហជីពអាចចែងលក្ខខណ្ឌសម្រាប់ការចូលរួមរបស់អ្នកចូលនិវត្តន៍ក្នុងមុខងារទាំងនេះផងដែរ។[២០]

ជាទូទៅសហជីពត្រូវបានទទួលស្គាល់ថាមានបុគ្គលភាពគតិយុត្ត និងភាពស្របច្បាប់លុះត្រាតែ សហជីពនោះបានចុះបញ្ជីរួច។[២១] ដូច្នេះហើយសហជីពត្រូវតែចុះបញ្ជីស្របតាមច្បាប់ស្តីពីសហជីពនៃព្រះរាជាណាចក្រកម្ពុជា។

[១៧] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៥។

[១៨] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៦។

[១៩] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៧។

[២០] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៨។

[២១] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១៤។

នៅពេលដែលច្បាប់ទទួលស្គាល់សហជីពមួយថាត្រឹមត្រូវស្របតាមច្បាប់ហើយ នោះវាក៏បានបង្កើតនូវសិទ្ធិ និងករណីយកិច្ចដល់សហជីពនោះផងដែរ។[២២] ហើយសហជីពត្រូវទៅចុះបញ្ជីនៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

ដើម្បីស្នើសុំចុះបញ្ជីសហជីព ច្បាប់បានកំណត់នូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ៖

- សម្រាប់សហជីពមូលដ្ឋាននៃសហគ្រាស ឬគ្រឹះស្ថានដែលនៅតាមបណ្តាខេត្ត ត្រូវ ដាក់សំណុំបែបបទសុំចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមខេត្តសាមីនោះ។
- ចំណែកឯសហជីពមូលដ្ឋាននៃសហគ្រាស ឬគ្រឹះស្ថានដែលនៅរាជធានីភ្នំពេញ សហជីពថ្នាក់សហព័ន្ធឡើងទៅ ត្រូវដាក់សំណុំបែបបទសុំចុះបញ្ជីនៅ នាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[២៣]

ចំពោះលក្ខខណ្ឌតម្រូវការស្នើសុំចុះបញ្ជីសហជីពវិញ ច្បាប់បានកំណត់ ឯកសារចាំបាច់ដើម្បីអាចស្នើសុំចុះបញ្ជី រួមមាន ៖

- ✓ ច្បាប់ដើមលក្ខន្តិកៈរបស់សហជីព រាប់បញ្ចូល ទាំងសេចក្តីថ្លែងការណ៍ស្តីពីគោលបំណងខ្លួន
- ✓ ច្បាប់ដើមបទបញ្ជាផ្ទៃក្នុងរដ្ឋបាល គ្រប់គ្រងទៅលើការដឹកនាំ និងកិច្ចការរដ្ឋបាល
- ✓ បញ្ជីរាយនាមដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល
- ✓ អាសយដ្ឋានសម្រាប់ថែរក្សាទុកសៀវភៅហិរញ្ញវត្ថុ កំណត់ត្រាហិរញ្ញវត្ថុ
- ✓ កិច្ចសន្យាធានាថានឹងផ្តល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានការចុះបញ្ជី
- ✓ ភ្ជាប់មកជាមួយកំណត់ហេតុច្បាប់ដើមនៃការបោះឆ្នោតបង្កើតអង្គការវិជ្ជាជីវៈ។

ហើយសម្រាប់លក្ខន្តិកៈរបស់សហជីពវិញ ច្បាប់បានកំណត់ផងដែរ នូវចំណុចសំខាន់ដែលត្រូវតែមានសរសេរនៅក្នុងនោះ ដែលមានដូចជា ៖

- ✓ ឈ្មោះ គំរូសញ្ញា អាសយដ្ឋាន និងគំរូត្រានៃសហជីព
- ✓ សេចក្តីពិពណ៌នាអំពីដែនអនុវត្តតាមវិជ្ជាជីវៈ ឬតាមវិស័យនៃសហជីព

[២២] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១១។

[២៣] ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក, លេខ ២៤៩ ក.ប/ប្រក, ២៧ មិថុនា ២០១៦, ប្រការ២ (ពីពេលនេះទៅហៅថា ប្រកាសស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក)។

- ✓ ត្រូវកំណត់ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុជាធម្មតា និងការបោះពុម្ពផ្សាយជាប្រចាំនូវរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់សហជីព
- ✓ ត្រូវកំណត់ចំនួនកូរ៉ុមប្រជុំចំនួនភាគច្រើនដាច់ខាត(ចំនួនយ៉ាងតិច ៥០%+១) នៃសមាជិក សហជីពសរុបសម្រាប់រាល់កិច្ចប្រជុំសម្រេចធ្វើកូដកម្ម កែប្រែលក្ខន្តិកៈ និងមហាសន្និបាតរបស់សហជីព
- ✓ លក្ខខណ្ឌតម្រូវឱ្យមានការបោះឆ្នោតជាសម្ងាត់ដោយសំឡេងយ៉ាងតិច៥០%+១ (ហាសិបភាគរយបូកមួយ) នៃសមាជិកដែលចូលរួមកិច្ចប្រជុំសម្រេចធ្វើកូដកម្ម នីតិវិធីសម្រាប់ជ្រើសរើសថ្នាក់ដឹកនាំតាមរយៈការបោះឆ្នោតជាសម្ងាត់
- ✓ ការកំណត់អាណត្តិសម្រាប់មុខតំណែងអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលជាមួយនឹងលទ្ធភាពនៃការជាប់ឆ្នោតសារជាថ្មី
- ✓ ការកំណត់ចំនួនប្រាក់ភាគទានដែលសមាជិកម្នាក់ៗត្រូវតែបង់និងបែបបទនៃការបង់ប្រាក់ ភាគទានប្រចាំខែ ត្រូវកំណត់ដោយមហាសន្និបាត ឬសន្និបាតរបស់សហជីព
- ✓ លក្ខណៈសម្បត្តិសម្រាប់ដឹកនាំគ្រប់គ្រង និងទទួលខុសត្រូវកិច្ចការរដ្ឋបាលយ៉ាងហោចណាស់ឱ្យស្របតាមមាត្រា២០ (លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន) នៃច្បាប់ស្តីពីសហជីព។[២៤]

បន្ទាប់ពីបំពេញទៅតាមលក្ខខណ្ឌតម្រូវ ការស្នើសុំចុះបញ្ជីសហជីព និងលក្ខខណ្ឌតម្រូវលក្ខន្តិកៈរបស់សហជីព សហជីពត្រូវអនុវត្តទៅតាមនីតិវិធី និងបែបបទក្នុងការចុះបញ្ជី ដើម្បីទទួលបាន បុគ្គលភាពគតិយុត្តស្របទៅតាមច្បាប់។ ដោយដាក់ពាក្យសុំនៅអង្គភាពទទួលបន្ទុកចុះបញ្ជីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អង្គភាពទទួលបន្ទុកត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជី និងលិខិតបញ្ជាក់ការចុះបញ្ជីដល់សហជីពយ៉ាងយូរ ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយទទួលបានសំណុំលិខិតសុំចុះបញ្ជីត្រឹមត្រូវ។ ក្នុងករណីមិនមានការឆ្លើយតបក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ សហជីពនោះត្រូវចាត់ទុកថាបានចុះបញ្ជីរួចហើយ។ អង្គភាពទទួលបន្ទុកចុះបញ្ជីត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជី និងលិខិតបញ្ជាក់ការចុះបញ្ជី ជូនសហជីពនោះ។[២៥]

ប៉ុន្តែប្រសិនបើក្រោយរយៈពេល៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានដាក់សំណុំបែបបទសុំចុះបញ្ជីត្រឹមត្រូវ សហជីព ដែលបានចាត់ទុកថាបានចុះបញ្ជីរួច នៅមិនទាន់ទទួលបានវិញ្ញាបនបត្រចុះបញ្ជី និង លិខិតបញ្ជាក់ការចុះបញ្ជី អាចដាក់លិខិតស្នើសុំវិញ្ញាបនបត្រចុះបញ្ជី និងលិខិតបញ្ជាក់ការចុះបញ្ជី ទៅ

[២៤] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១៣។

[២៥] ប្រកាសស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក, ប្រការ៤។

អង្គភាព ទទួលបន្ទុកចុះបញ្ជី។ ក្នុងករណីមិនមានចម្លើយតបក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ សហជីព អាចធ្វើឧបាស្រ័យអំពីករណីនេះទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[២៦]

ក្រោយពីការចុះបញ្ជី សហជីព ត្រូវចម្លងជូនអង្គភាពទទួលបន្ទុកចុះបញ្ជី នូវរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សកម្មភាពប្រចាំឆ្នាំ ដើម្បីរក្សាបញ្ជិការបស់ខ្លួន ដោយមានរយៈពេលយ៉ាងយូរត្រឹមដំណាច់ខែមីនា នៃឆ្នាំបន្ទាប់តាមទម្រង់បែបបទដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ បញ្ជិការបស់សហជីពមួយអាចជា កម្មវត្ថុនៃការប្តឹងលុបបញ្ជិកា ដូចមានចែងក្នុងករណីសហជីពណាមួយ ដែលបានខកខានក្នុងការធ្វើបច្ចុប្បន្នកម្ម ជូនអង្គភាពទទួលបន្ទុកចុះបញ្ជីដូចមានតម្រូវក្នុងមាត្រា១៧ នៃច្បាប់ស្តីពីសហជីព។[២៧]

ចំពោះសហជីព ដែលបានចុះបញ្ជីរួចហើយមុនច្បាប់ស្តីពីសហជីពចូលជាធរមាន(មុនឆ្នាំ២០១៦) ត្រូវ ចាត់ទុកថាបានចុះបញ្ជីរួច និងទទួលបានដោយស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិ នៃ ច្បាប់ស្តីពីសហជីព រហូតដល់ចប់អាណត្តិរបស់ខ្លួន ដោយត្រូវអនុវត្តតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៣ នៃច្បាប់ស្តីពីសហជីព។

ថ្វីបើមូលដ្ឋានច្បាប់អនុញ្ញាតឱ្យ កម្មករនិយោជិតដែលធ្វើការតាមសហគ្រាស គ្រឹះស្ថាននានា មានសិទ្ធិ បង្កើតអង្គការវិជ្ជាជីវៈសម្រាប់តំណាងពួកគេក៏ដោយ ប៉ុន្តែអង្គការវិជ្ជាជីវៈ ទាំងនោះពុំទទួលបាននូវសិទ្ធិ និង ផលប្រយោជន៍ពីច្បាប់សហជីពនោះឡើយ ប្រសិនបើពួកគេពុំបានចុះបញ្ជីនៅក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ។

ប្រសិនបើយើងនិយាយអំពីការរំលាយសហជីពវិញ សហជីព អាចត្រូវបានរំលាយបានតាមវិធី ណាមួយ ដូចខាងក្រោម ៖

ក- សហជីព ត្រូវបានរំលាយដោយអនុលោមតាមលក្ខន្តិកៈរបស់សហជីពនីមួយៗ។

ខ- សហជីពមួយត្រូវបានរំលាយដោយស្វ័យប្រវត្តិក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានត្រូវបានបិទ លែងដំណើរការជាស្ថាពរ និងបានទូទាត់ជាស្ថាពរនូវប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិត។

[២៦] ប្រកាសស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក, ប្រការ៦។
[២៧] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១៨។

គ- សហជីព ត្រូវបានរំលាយចោលដោយតុលាការ។[២៨] សហជីពត្រូវបានរំលាយដោយតុលាការ ការងារនៅក្នុងមូលហេតុណាមួយដូចជា៖

- ការបង្កើត ឬសកម្មភាពនានារបស់សហជីព មានលក្ខណៈផ្ទុយនឹងច្បាប់ ឬគោលដៅនៃសហជីព ដូចមានចែងនៅក្នុងលក្ខន្តិកៈ។
- សហជីពដែលមិនមានលក្ខណៈឯករាជ្យពីនិយោជកដទៃទៀត ហើយជាក់ស្តែងមិនអាច ស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន។
- អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល ត្រូវបានរកឃើញថាមានកំហុស ធ្ងន់ក្នុងការប្រព្រឹត្តល្មើសក្នុងនាមសហជីព។[២៩]

ដោយឡែក ច្បាប់ការងារក៏បានចែងផងដែរថា អ្នកដឹកនាំ ឬអភិបាល នៃអង្គការវិជ្ជាជីវៈ ឬសហភាពអង្គភាព វិជ្ជាជីវៈ ដែលនាំអង្គការទាំងនោះឱ្យធ្វើសកម្មភាពផ្ទុយពីគោលដៅតែមួយគត់របស់ខ្លួនដូចមានចែងនៅក្នុងមាត្រា ២៦៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីហុកសិបមួយថ្ងៃ ទៅកៅសិបថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។

ការរំលាយចោលអង្គការវិជ្ជាជីវៈ ឬសហភាពអង្គការវិជ្ជាជីវៈ ត្រូវប្រកាសដោយតុលាការការងារក្នុងករណី ដែលអង្គការទាំងនោះបានធ្វើសកម្មភាពខុសឆ្គងដូចមានចែងក្នុងកថាខណ្ឌខាងលើ ឬក្នុងករណីដែលបំពានយ៉ាង ធ្ងន់ធ្ងរនិងធ្ងួនៗលើច្បាប់ និងបទបញ្ជាទាំងឡាយពិសេសក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈ។[៣០]

កម្មករនិយោជិតដែលជាសមាជិកនៃសហជីពទាំងអស់ អាចចូលរួមក្នុងការងារដឹកនាំ ការងារគ្រប់គ្រង និង ការងាររដ្ឋបាលរបស់សហជីពទាំងនោះបាន។ ចំពោះលក្ខណសម្បត្តិរបស់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវ កិច្ចការរដ្ឋបាលរបស់សហជីព ដែលជាពលរដ្ឋខ្មែរ ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច ១៨ឆ្នាំ
- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់
- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមានកម្រិតវប្បធម៌យ៉ាងហោចណាស់ចេះអាន ចេះសរសេរ អក្សរខ្មែរ។
- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

[២៨] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព, លេខ នស/រកម/០១២០/00១, ០៣ មករា ២០២០, មាត្រា២៨ថ្មី (ពីពេលនេះតទៅហៅ ថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព ឆ្នាំ២០២០)។

[២៩] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព ឆ្នាំ២០២០, មាត្រា២៩ថ្មី។

[៣០] ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១, ១៣ មីនា ១៩៩៧, មាត្រា ៣៧៨ (ពីនេះតទៅហៅថា ច្បាប់ស្តីពីការងារ)។

នៅក្នុងច្បាប់ស្តីពីការងារ បានកំណត់អំពីលក្ខណសម្បត្តិរបស់អ្នកដឹកនាំសហជីពនេះផងដែរ ដោយបានកំណត់អំពីលក្ខណសម្បត្តិនៃអាយុ គឺអាយុ២០ឆ្នាំ ដោយនៅក្នុងច្បាប់ស្តីពីសហជីព កំណត់ត្រឹមតែអាយុ១៨ឆ្នាំ តែប៉ុណ្ណោះ និងការកំណត់អំពីការប្រកបវិជ្ជាជីវៈយ៉ាងតិចចំនួនមួយឆ្នាំ ដោយនៅក្នុងច្បាប់ស្តីពីសហជីព មិនបានកំណត់អំពីលក្ខណនៃការប្រកបវិជ្ជាជីវៈនោះទេ។ បន្ថែមពីនេះ ច្បាប់ស្តីពីសហជីព ដូចជាបានបន្ថែមលក្ខខណ្ឌមួយទៀត គឺត្រូវធ្វើសេចក្តីប្រកាសអំពី អាសយដ្ឋានរស់នៅ។

មិនតែប៉ុណ្ណោះសូម្បីតែជនបរទេសក៏អាចចូលរួមកិច្ចការនេះបានដែរ។ ចំពោះអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព ដែលជាជនបរទេសត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- មានអាយុយ៉ាងតិច ១៨ឆ្នាំ
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- បាន និងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ២ឆ្នាំ
- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- មានសិទ្ធិស្នាក់នៅ និងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាត្រឹមត្រូវតាម ច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។

## ១.២.ប្រវត្តិ និង ការវិវត្តនៃសហជីពនៅកម្ពុជា

មុននឹងបកស្រាយពីសញ្ញាណទូទៅនៃសហជីព យើងគួរចោទសួរជាមុនសិនថា ហេតុអ្វីចាំបាច់មានវត្តមានរបស់សហជីពក្នុងបរិបទនៃនីតិការងារ និង ហេតុអ្វីចាំបាច់មានការចងក្រងនូវ ច្បាប់ស្តីពីសហជីពដើម្បីការពារនូវសិទ្ធិរបស់សហជីពតាមផ្លូវច្បាប់?

### ១.២.១.ស្ថានភាពការអនុវត្តសិទ្ធិសហជីពមុនមានច្បាប់ការងារ ឆ្នាំ១៩៩៧

ការផ្លាស់ប្តូររបបនយោបាយ និងសេដ្ឋកិច្ច នៅឆ្នាំ១៩៨៩ បានលើកទឹកចិត្តឱ្យកំណើតនៃសហជីពសេរី និងប្រជាធិបតេយ្យនៅកម្ពុជា។ រយៈពេលរវាងឆ្នាំ១៩៩១ និងឆ្នាំ១៩៩៣ យើងសង្កេតឃើញថា មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ពីផែនការសេដ្ឋកិច្ចកណ្តាល ទៅជាសេដ្ឋកិច្ចទីផ្សារសេរី។ រដ្ឋាភិបាលកម្ពុជាក៏ផ្លាស់ប្តូរគោលនយោបាយទីផ្សាររបស់ខ្លួន ដោយសហការជាមួយអន្តរជាតិ មូលនិធិរូបិយវត្ថុ ធនាគារពិភពលោក ប្រទេសម្ចាស់ជំនួយ និងអង្គការអន្តរជាតិ។[៣១]

[៣១] នួន វាសនា និង Melisa Serrano, ការកសាងសហជីពនៅប្រទេសកម្ពុជា៖ កាលប្បវត្តិ ការប្រឈម និងយុទ្ធសាស្ត្រ (ប្រទេសសិង្ហបុរី៖ Friedrich-Ebert-Stiftung, ២០១០), ទំព័រទី២៣។

ចាប់តាំងពីឆ្នាំ១៩៩០មក សហជីពដែលកាន់កាប់ដោយរដ្ឋត្រូវបានរំសាយដើម្បីដើរតាមចំណុចរបត់នៃនយោបាយថ្មីរបស់ប្រទេស។ សហព័ន្ធសហជីពកម្ពុជា ជាសហជីពតែមួយគត់នៅក្នុងរបបសង្គមនិយមដែលត្រូវបានផ្លាស់ប្តូរទៅជាអង្គការមហាជន។ ចំពោះមេដឹកនាំភាគច្រើននៅក្នុងសហជីពមួយនេះ ត្រូវបានរដ្ឋចាត់តាំងឱ្យទៅបម្រើការងារនៅតាមក្រសួងផ្សេងៗពីគ្នា។ ឯបណ្តាអ្នកដឹកនាំមួយចំនួនទៀត បានធ្វើការស្ម័គ្រចិត្តទទួលយកតំណែងជាអ្នកដឹកនាំនៅក្នុងអង្គការមហាជន ដោយបានប្រមូលចងក្រងកម្មករនៅតាមបណ្តារោងចក្រសហគ្រាស។ បន្ថែមទៅលើនេះទៀត នៅឆ្នាំ១៩៩៦ មានសហជីពមួយត្រូវបានបង្កើតឡើងដោយមាន ឈ្មោះថា សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលជាសហជីពដំបូងគេបង្អស់ក្រោយ មានការផ្លាស់ប្តូររបបសេដ្ឋកិច្ចទីផ្សារសេរី។ នៅរយៈពេលក្រោយៗមកទៀត សហជីពជាច្រើនត្រូវ បានបង្កើតឡើងនៅតាមមូលដ្ឋាន។[៣២]

## ១.២.២.ស្ថានភាពការអនុវត្តសិទ្ធិសហជីពចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១៦

ក្នុងឆ្នាំ១៩៩៩ កម្ពុជាមានរោងចក្រកាត់ដេរប្រមាណជាង១០០ និងមានសហព័ន្ធសហជីពចំនួន៤ គឺសហព័ន្ធសហជីពឯករាជ្យកម្ពុជា(CFITU) សហព័ន្ធសហជីពខ្មែរ(CUF) សហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា(FTUWKC) និងសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា(NIFTUC)។ សហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធសហជីពខ្មែរត្រូវបានបង្កើតឡើងមុនគេ នៅឆ្នាំ១៩៩៧។ ចំណែក សហព័ន្ធសហជីពកម្មករកម្ពុជា (CLUF) ត្រូវបានចុះបញ្ជីនៅឆ្នាំ១៩៩៨ ហើយ រយៈពេលពេលមួយឆ្នាំក្រោយមក សហព័ន្ធសហជីពឯករាជ្យកម្ពុជា និង សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា ក៏ត្រូវបានបង្កើតឡើង។ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា ត្រូវបានស្គាល់ថាជាសហជីពដែលរៀបចំឱ្យមានកូដកម្មនៅតាមបណ្តារោងចក្រកាត់ដេរ ហើយជាញឹកញាប់មានការប្រឈមមុខដាក់គ្នា និងការប្រកួតប្រជែងរវាងសហជីព និងសហជីពដែលមាននិន្នាការនយោបាយផ្សេងៗគ្នា។[៣៣]

ពីរឆ្នាំក្រោយមក សម្រាប់កម្មករនៅក្រៅក្របខ័ណ្ឌច្បាប់ការងារ អាចជាកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬជាមន្ត្រីរាជការ។ នៅឆ្នាំ២០០០ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា  សហព័ន្ធសហជីពការងារកម្មករកម្ពុជា សហព័ន្ធសហជីពការងារកម្មករកម្ពុជា សហព័ន្ធសហជីពសេរីពលករខ្មែរ និងសហព័ន្ធសហជីពយុវជនខ្មែរត្រូវបានបង្កើតឡើង។ ឯនៅឆ្នាំ២០០១ សហព័ន្ធសហជីពសាមគ្គីភាព សហព័ន្ធសហជីពនៃកម្មករសំណង់ និងព្រៃឈើ សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករ

---

[៣២] ដដែល, ទំព័រទី២៤។

[៣៣] ដដែល, ទំព័រទី២៥។

និយោជិតខ្មែរ និងសមាគមកម្ពុជាដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានចុះបញ្ជី។ នៅឆ្នាំ២០០២ សហព័ន្ធសហជីពធម្មាធិបតេយ្យក៏ត្រូវបានបង្កើតឡើងផងដែរ។[៣៤]

រហូតដល់ឆ្នាំ២០០៣ សហភាពកម្មករពិភពលោកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក(ITUC-AP) ដោយមានការគាំទ្រពីគម្រោងអប់រំសហជីពនៃអង្គការពលកម្មអន្តរជាតិ (ILO-WEP) បានចាប់ផ្តើមធ្វើការងារជាមួយបណ្តាសហព័ន្ធនានាដែលស្ថិតនៅក្នុងក្រុម A និងក្រុម B។ ចំពោះក្រុម B បានបែងចែកជា ៣ សហភាពគឺ សហភាពសហជីពកម្ពុជា សហភាពការងារកម្ពុជា និងសម្ព័ន្ធសហព័ន្ធសហជីពការងារជាតិកម្ពុជា។ សហភាពសហជីពកម្ពុជា មានសហព័ន្ធ២ទៀត គឺសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកសហភាពការងារកម្ពុជា គឺត្រូវបានបង្កើតឡើង ដោយសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា នៅឆ្នាំ២០០៦ និង សម្ព័ន្ធសហព័ន្ធសហជីពការងារជាតិកម្ពុជាដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ដោយសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា។ នៅឆ្នាំ២០០៦ សហជីពដែលគាំទ្ររដ្ឋាភិបាលបានបែកបាក់គ្នាបន្ទាប់ពីបានធ្វើការប្រារព្ធនូវសន្និបាតរបស់ខ្លួន ហើយជាលទ្ធផល សម្ព័ន្ធភាពសហភាពថ្មី មួយដែលមានឈ្មោះថា សភាសម្ព័ន្ធសហជីពជាតិកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧។[៣៥]

### ១.២.៣.ស្ថានភាពការអនុវត្តសិទ្ធិសហជីពចាប់ពីឆ្នាំ២០១៦

ច្បាប់ស្តីពីសហជីព ត្រូវបានប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រមលេខ នស/រកម/០៥១៦/00៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលបានក្លាយទៅជាច្បាប់ដ៏មានសារៈសំខាន់ក្នុងការធានាសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការងារ។ ឈរលើមូលដ្ឋានគតិយុត្តទាំងនេះ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង ដែលចាំបាច់តម្រូវឱ្យមានបទប្បញ្ញត្តិមួយកាន់តែច្បាស់លាស់ ដើម្បីកាន់តែធានាបាននូវភាពប្រសើរឡើងនៃការអនុវត្តសិទ្ធិនេះជានិច្ច។

ច្បាប់ស្តីពីសហជីពត្រូវបានបង្កើតឡើងក្រោមគោលបំណង៣។ ទី១.ផ្តល់សិទ្ធិនិងសេរីភាពដល់សហគ្រាសឬគ្រឹះស្ថាន និងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ និងកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទី២.ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនទាំងឡាយដែល ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ។ និងទី៣ធានានូវ សិទ្ធិសេរីភាពក្នុងការចរចាជាសមូហភាពរវាងកម្មករនិយោជិត និងនិយោជក ព្រមទាំងជំរុញឱ្យ

[៣៤] ដដែល, ទំព័រទី២៧។

[៣៥] ដដែល, ទំព័រទី២៧។

មានសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងរួមចំណែកក្នុងការអភិវឌ្ឍការងារសមរម្យ ដើម្បីបង្កើនផលិតភាព និងការវិនិយោគ។

# ជំពូកទី២
# សិទ្ធិរបស់សហជីព និង
# ភាពជាតំណាងបំផុតនៅកម្ពុជា

# ជំពូកទី២
# សិទ្ធិរបស់សហជីព និងភាពជាតំណាងបំផុតនៅកម្ពុជា

ដូចដែលបានលើកឡើងខាងលើថា ក្រោយពីសហជីពបានចុះបញ្ជីរួចគេនឹងទទួលបានសិទ្ធិ និងកាតព្វកិច្ច ស្របតាមច្បាប់។ ដូច្នេះមុននឹងឈានទៅដល់ ការសិក្សាពីភាពជាអ្នកតំណាងបំផុត របស់សហជីពក៏ដូចជាកាតព្វកិច្ចរបស់សហជីព យើងគប្បីយល់ដឹងអំពីសិទ្ធិរបស់សហជីពជាទូទៅ ថាតើសហជីពទទួលបាននូវសិទ្ធិតាមច្បាប់អ្វីខ្លះ?

## ២.១.សិទ្ធិរបស់សហជីព

### ២.១.១.សិទ្ធិក្នុងការតំណាង

សហជីពបង្កើតឡើងដើម្បីធ្វើជាតំណាងឱ្យកម្មករនិយោជិត ដែលជាសមាជិករបស់ខ្លួន ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ដូចជាចូលរួមក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា ចូលរួមពិគ្រោះយោបល់ជាមួយនិយោជកដោយសេរី និងធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលដៅលើកតម្កើង និងការពារផលប្រយោជន៍ខាងផ្នែកស្មារតី និងសម្ភារដល់សមាជិករបស់ខ្លួន ពិគ្រោះពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាង ឬកែសម្រួលបទបញ្ជាផ្ទៃក្នុង និងពិគ្រោះពិភាក្សា ព្រមទាំងវិធានការសម្រាប់ការបញ្ឈប់កម្មករនិយោជិតដោយសារការកាត់បន្ថយសកម្មភាពការងារ។[៣៦]

### ២.១.២.សិទ្ធិទទួលបានបញ្ជិកា

សហជីពដែលបានបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់ដោយច្បាប់ស្តីពីសហជីព ត្រូវទទួលបានបញ្ជិកានៃការអនុញ្ញាតចុះបញ្ជី ដើម្បីបញ្ជាក់អំពីការចាប់ផ្តើមបង្កើតនូវសិទ្ធិ និងទទួលបានផលប្រយោជន៍ដែលមានចែងក្នុងច្បាប់ ដើម្បីបំពេញបេសកកម្មរបស់ខ្លួនក្នុងការការពារសិទ្ធិកម្មករនិយោជិត ស្របតាមលក្ខន្តិកៈសហជីព។[៣៧] សូមបញ្ជាក់ផងដែរថា សហជីពដែលមានបញ្ជិកាចុះបញ្ជី មិនអាចប្រកបរបរជំនួញទេ វៀរលែងតែសកម្មភាពស្របច្បាប់ដែលមានចែងក្នុង ចំណុច "ឆ" នៃមាត្រា ៥៩ (សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុត) នៃច្បាប់ស្តីពីសហជីព។[៣៨]

[៣៦] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១០។
[៣៧] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១១។
[៣៨] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១៤។

### ២.១.៣.សិទ្ធិក្នុងការចងសម្ព័ន្ធភាព

សហជីពអាចចងសម្ព័ន្ធភាពជាមួយសហជីពផ្សេងៗទៀតបានជាលក្ខណៈជាតិ និងអន្តរជាតិ។[៣៩] ការចងសម្ព័ន្ធនេះ ផ្តល់ឱកាសឱ្យសហជីពពង្រីកវិសាលភាពនៃបណ្តាញការងារ ការស្រាវជ្រាវ ការបណ្តុះបណ្តាលទម្ងន់នៃការចរចា ពិសេសកិច្ចសហប្រតិបត្តិការដើម្បីការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត។ ប៉ុន្តែ សហជីពមួយនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយ មានសិទ្ធិចូលរួមជាសមាជិកភាពក្នុងសហជីពដែលមានកម្រិតខ្ពស់ជាងខ្លួនបានតែក្នុងអំឡុងពេលតែមួយប៉ុណ្ណោះ។

### ២.១.៤.សិទ្ធិក្នុងការប្រមូលវិភាគទាន

យោងតាមមាត្រា២៦ នៃច្បាប់ស្តីពីសហជីព (ការកាត់ប្រាក់ភាគទាន និងប្រាក់សេវាភ្នាក់ងារដែលមានការអនុញ្ញាត) និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីព ដើម្បីផ្ទេរទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត។ បែបបទអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ សហជីពមានភាពជាតំណាងបំផុតដែលតំណាងឱ្យកម្មករនិយោជិតទាំងអស់មានសិទ្ធិផ្តាច់មុខក្នុងការចរចា ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវការកំណត់តម្លៃសេវាភ្នាក់ងារសមរម្យឯកភាពមួយ ដែលមិនលើសពីប្រាក់ភាគទាន និងតម្លៃផ្សេងទៀត។ តម្លៃសេវាភ្នាក់ងារនេះត្រូវបានបង់តែម្តងគត់។

ការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់បង់ភាគទានសហជីពដោយនិយោជក ត្រូវធ្វើឡើងទៅតាមចំនួនប្រាក់ភាគទាន និងបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែ ដែលត្រូវបានកំណត់ជាមុននៅក្នុងលក្ខន្តិកៈរបស់សហជីពដែលកម្មករនិយោជិតសាមីជាសមាជិក។ កាលបរិច្ឆេទនៃការកាត់ប្រាក់ឈ្នួលសម្រាប់បង់ជាភាគទានសហជីព ត្រូវកំណត់ឡើងឱ្យដូចគ្នានឹងកាលបរិច្ឆេទនៃថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមី។ សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជក ឱ្យបានយ៉ាងតិច១០(ដប់)ថ្ងៃមុនការចាប់ផ្តើមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានសហជីពដែលនឹងត្រូវកាត់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន។ សហជីពត្រូវភ្ជាប់មកជាមួយនូវលិខិតយល់ព្រម ឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព ដែលមានចុះកាលបរិច្ឆេទនិងហត្ថលេខាឬស្នាមម្រាមដៃ របស់កម្មករនិយោជិតសាមី។[៤០]

[៣៩] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១០។

[៤០] ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ, លេខ ៣០០ កប/ប្រក.កបក, ២ កក្កដា ២០១៨, ប្រការ៤។

កម្មករនិយោជិតអាចបដិសេធវិញបានគ្រប់ពេលវេលា ចំពោះការកាត់ប្រាក់ឈ្នួលរបស់ខ្លួនសម្រាប់បង់ភាគទានសហជីព ដោយត្រូវធ្វើលិខិតបដិសេធជូនសហជីពដែលខ្លួនជាសមាជិកចំនួន ០១(មួយ)ច្បាប់ ឱ្យបានយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃបើកប្រាក់ឈ្នួល។ បន្ទាប់ពីទទួលបានលិខិតបដិសេធ សហជីពសាមីត្រូវចម្លងលិខិតបដិសេធនោះជូននិយោជកឱ្យបានយ៉ាងតិច ០៥(ប្រាំ)ថ្ងៃ មុនថ្ងៃបើកប្រាក់ឈ្នួល។[៤១]

## ២.១.៥.សិទ្ធិទទួលបានការការពារពិសេស

កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើស ថ្នាក់ដឹកនាំគ្រប់គ្រងសហជីព ទទួលបាននូវការការពារពីការរងគ្រោះ និងការបញ្ឈប់ពីការងារទេ។[៤២] ការការពារនេះមានរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ មុនការបោះឆ្នោត តែបើក្នុងករណីដែលបេក្ខជនឈរឈ្មោះនោះ ពុំបានទទួលសម្លេង គាំទ្រពីសំណាក់អ្នកចូលរួមបោះឆ្នោតនោះទេ សិទ្ធិពិសេសនេះក៏នៅតែបន្តការពារគេក្នុងរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃទៀត។[៤៣] ដែលមានន័យថា ក្នុងអំឡុងពេលមុន និងក្រោយការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រងសហជីព កម្មករនិយោជិតដែលជាបេក្ខជនឈរឈ្មោះនឹងមិនត្រូវបានបញ្ឈប់ពីការងារទេ។ ហើយដើម្បីទទួលបានការការពារពិសេសនេះ សហជីពត្រូវជូនដំណឹងទៅនិយោជក និងថតចម្លងឯកសារជូនដំណឹងនោះជូនទៅក្រសួងទទួលបន្ទុកវិស័យការងារអំពីបេក្ខភាព ដែលត្រៀមឈរឈ្មោះ និងទុកជាបានការ។ និយោជកក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិផងដែរ។ ហើយចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជីសហជីពទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិត ដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជីត្រូវទទួលបានការការពារដូចគ្នាផងដែរ។ ហើយការការពារនេះមានរយៈពេលរហូតដល់៣០(សាមសិប)ថ្ងៃក្រោយ កាលបរិច្ឆេទដែលក្រសួងទទួលបន្ទុកវិស័យការងារបញ្ជាក់អំពីបញ្ជិកាសហជីព ដែលមានន័យថា កម្មករនិយោជិតដែលជាសមាជិកសហជីពក៏ត្រូវទទួលបានសិទ្ធិការពារពិសេសនេះផងដែរ។ នៅពេលផុតរយៈពេលកំណត់នេះ ការការពារនេះត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ដែលមានប្រធាន អនុប្រធាន១(មួយ)រូប និងលេខាធិការរបស់សហជីព។ សហជីពត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នក ដែលត្រូវទទួលបាននូវ

---

[៤១] ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ, ប្រការ៥។

[៤២] ច្បាប់ស្តីពីសហជីព, មាត្រា៦៤។

[៤៣] ច្បាប់ស្តីពីសហជីព, មាត្រា៦៤។

ការការពារតាមគ្រប់មធ្យោបាយដែលទុកជាបានការ។ សេចក្តីចម្លង១(មួយ)ច្បាប់នៃការជូនដំណឹងនេះត្រូវផ្ញើទៅក្រសួងទទួលបន្ទុកវិស័យការងារ។[៤៤]

## ២.២.ភាពជាតំណាងបំផុតនៃសហជីព

ជាទូទៅ ការងារសហជីពគឺអាចការពារទាំងសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត បានមួយចំណែកធំហើយ ដូចជា ការតំណាងក្នុងការទាមទារ, ការចរចា ឬការតំណាងក្នុងការដោះស្រាយវិវាទជាអាទិ៍។[៤៥] ក៏ប៉ុន្តែ សហជីពទូទៅពួកគេពុំមានសិទ្ធិអាចចងក្រងនូវអនុសញ្ញារួមដែលជាសិទ្ធិផ្តាច់មុខ របស់សហជីពតំណាងបំផុត បានទេ។ ហើយក្នុងចំណុចនេះ យើងនឹងសិក្សាពីសារៈសំខាន់របស់សហជីពតំណាងបំផុត និងសារៈសំខាន់ក្នុងការចងក្រងបង្កើតអនុសញ្ញារួម ក៏ដូចជាការដោះស្រាយវិវាទការងារ។

### ២.២.១.ប្រភេទនៃភាពជាតំណាងបំផុត

សម្រាប់ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស គ្រឹះស្ថានដើម្បីទទួលបានភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន សហជីពត្រូវបំពេញគ្រប់លក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក- បានចុះបញ្ជីត្រឹមត្រូវ

ខ- មានកម្មវិធី និងសកម្មភាពដែលបង្ហាញថាសហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួនដូចមានចែងនៅក្នុងច្បាប់ស្តីពីសហជីព

គ- មានសមាជិកដែលមានបណ្ណសម្គាល់ និងបញ្ជីឈ្មោះសមាជិកត្រឹមត្រូវច្រើនជាងគេ ឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយដូចករណីខាងក្រោម ៖

- សហជីពដែលមានសមាជិកចាប់ពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពតែមួយ ឬ
- សហជីពណាដែលស្វែងរកបានការគាំទ្រពីសហជីពដទៃច្រើនជាងគេបំផុតដោយលើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប ក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពលើសពី ១ (មួយ) ឬ
- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របានចាប់ពី ៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រឱ្យបានសំឡេងច្រើនជាងគេ

[៤៤] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៦៧។
[៤៥] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៥៩។

បំផុតលើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថាននោះ។ បែបបទអនុវត្តនៃការបោះឆ្នោតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

- ប្រសិនបើនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយមានសហជីពមូលដ្ឋានច្រើនផ្សេងៗគ្នា មិនអាចបំពេញគ្រប់លក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា ៧២ (ក្រុមប្រឹក្សាចរចា) នៃច្បាប់នេះ។[៤៦]

ចំណែកឯ ភាពជាតំណាងបំផុតនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយ ដែលមានសហជីពច្រើន សហជីពទាំងនេះត្រូវតែស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុត ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងចំណុច "ក" និង"ខ" នៃមាត្រា៥៤ថ្មី(ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន) នៃច្បាប់ស្តីពីសហជីព ដោយបូកបន្ថែមលក្ខណៈវិនិច្ឆ័យមួយទៀត គឺត្រូវមានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានចាប់ពី ៣០%(សាមសិប ភាគរយ) នៃចំនួនកម្មករនិយោជិតទាំងអស់នៅក្នុងវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យ ដែលសហជីពដាក់ពាក្យសុំបញ្ជាក់ភាពជាតំណាងបំផុត។

សហជីពដែលមានភាពជាតំណាងបំផុតមានសិទ្ធិផ្តាច់មុខក្នុងការតំណាងឱ្យកម្មករនិយោជិត ទាំងអស់ដើម្បីធ្វើការចរចាចុះអនុសញ្ញារួមឬដោះស្រាយវិវាទការងាររួមជាមួយនិយោជកឬសមាគម និយោជកនៃវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យនោះ។ ប្រសិនបើនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយមានសហជីពច្រើនផ្សេងៗគ្នាដែលមិនអាចបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ ដូចមានចែងខាងលើ ពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា៧២ (ក្រុមប្រឹក្សាចរចា) នៃច្បាប់ស្តីពីសហជីព។[៤៧]

### ២.២.២.ការបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុត

ការបោះឆ្នោតជ្រើសរើសសហជីព ដែលមានភាពជាតំណាងបំផុតត្រូវធ្វើទៅតាមនីតិវិធីដូចខាងក្រោម៖

១- កម្មករនិយោជិតពេញសិទ្ធិទាំងអស់នៃសហគ្រាស គ្រឹះស្ថាន មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត។

[៤៦] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព ឆ្នាំ២០២០, មាត្រា៥៤ថ្មី។

[៤៧] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព ឆ្នាំ២០២០, មាត្រា៥៥ថ្មី។

២-សហជីពអាចធ្វើយុទ្ធនាការឃោសនាអំពីព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបោះឆ្នោត រួមទាំងកម្មវិធីការងាររបស់ខ្លួននៅពេលទទួលបានភាពជាតំណាងបំផុតដល់កម្មករនិយោជិត ដើម្បីជាមូលដ្ឋានក្នុងការបោះឆ្នោត។ ការធ្វើយុទ្ធនាការនេះត្រូវប្រព្រឹត្តទៅនៅក្រៅម៉ោងធ្វើការ ឬក្នុងម៉ោងធ្វើការ នៅក្នុងសហគ្រាស គ្រឹះស្ថាន ប្រសិនបើមានការយល់ព្រមពីនិយោជក និងស្របតាមបែបបទដែលនិយោជកបានយល់ព្រម។

៣-សហជីពអាចកំណត់ឱ្យមានអ្នកសង្កេតការណ៍ដែលអាចជាតំណាងសហព័ន្ធសហជីព សហភាពសហជីព ឬក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យដំណើរការនៃការបោះឆ្នោតនេះ។

៤-ការបោះឆ្នោតត្រូវធ្វើជាសម្ងាត់។

៥-សន្លឹកឆ្នោតត្រូវរាប់ និងប្រកាសលទ្ធផលជាសាធារណៈ បន្ទាប់ពីការបោះឆ្នោតនេះបានបញ្ចប់រួចភ្លាម។

៦-កំណត់ហេតុនៃការបោះឆ្នោតនេះត្រូវចុះហត្ថលេខាពីគ្រប់តំណាងសហជីពដែលបានចូលរួម។

ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុតនេះ និយោជកត្រូវបង្កលក្ខណៈងាយស្រួលដល់កម្មករនិយោជិតពេញសិទ្ធិទាំងអស់ ដោយផ្តល់ពេលវេលានៅចុងម៉ោងការងារ ឬពេលវេលាណាមួយ ដែលទទួលបានការឯកភាពរវាងនិយោជកនិងគ្រប់សហជីពមូលដ្ឋានទាំងអស់ នៅក្នុងសហគ្រាស គ្រឹះស្ថាននោះ។ រាល់ការធ្វើបណ្តឹងទាក់ទងដល់ដំណើរការនៃការបោះឆ្នោត ឬលទ្ធផលបោះឆ្នោតនេះ ត្រូវដាក់ជូនទៅតុលាការការងារក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃប្រកាសលទ្ធផល។ ការធ្វើបណ្តឹងនេះមិនមានផលវិបាកធ្វើឱ្យផ្អាកការអនុវត្តលទ្ធផលនៃការបោះឆ្នោតឡើយ។[៤៨]

### ២.២.៣.ការស្នើសុំទទួលស្គាល់ភាពជាតំណាងបំផុតនៃសហជីព

សំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត មានដូចខាងក្រោមៈ

១- ពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត ចំនួន ០១ច្បាប់ដើម។

២-សេចក្តីថតចម្លងលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពចំនួន ០២ច្បាប់បើមាន។

៣- បញ្ជីឈ្មោះសមាជិកដែលមានបណ្ណសម្គាល់ត្រឹមត្រូវ ចំនួន ០២ច្បាប់។

[៤៨] ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីភាពជាតំណាងបំផុតនៃសហជីព , លេខ ៣០៣ កប/ប្រក.កបក, ២ កក្កដា ២០១៨, ប្រការ៤ (ពីពេលនេះតទៅហៅថា ប្រកាសពីភាពជាតំណាងបំផុតនៃសហជីព)។

៤- ក្នុងករណីមានការបោះឆ្នោត ត្រូវមានកំណត់ហេតុនៃការបោះឆ្នោត ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះសហជីពដែលឈរឈ្មោះ និងបញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុត ចំនួន០២ច្បាប់។[៤៩]

សហជីពត្រូវដាក់សំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត នៅអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដូចខាងក្រោម៖

១- ចំពោះសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថានដែលមានអាសយដ្ឋាននៅតាមបណ្តាខេត្ត ត្រូវដាក់នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តនោះ ដើម្បីបញ្ជូនមកនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២- ចំពោះសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថានដែលមានអាសយដ្ឋាននៅរាជធានីភ្នំពេញ ថ្នាក់សហព័ន្ធសហជីព និងថ្នាក់សហភាពសហជីព ត្រូវដាក់នៅនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[50]

មានតែអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលនៃសហជីពដែលស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតប៉ុណ្ណោះ ទើបមានសិទ្ធិក្នុងការយកសំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតនេះដាក់ជូនអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត។

ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ក្រោយពេលបានទទួលសំណុំបែបបទក្រសួងទទួលបន្ទុកវិស័យការងារត្រូវសម្រេចជាផ្លូវការអំពីការទទួលស្គាល់ភាពជាតំណាងបំផុតរបស់សហជីពដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងច្បាប់នេះ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចចាត់ឱ្យមានការអង្កេត ប្រសិនបើចាំបាច់ត្រូវពិនិត្យឡើងវិញភាពជាតំណាងបំផុតរបស់សហជីពណាមួយ។ ក្រសួងទទួលបន្ទុកវិស័យការងារ អាចព្យួរ ឬដកហូតភាពជាតំណាងបំផុតរបស់សហជីពក្នុង ករណីមានការរំលោភបំពាន ឬបាត់បង់លក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។[៥១]

[៤៩] ប្រកាសពីភាពជាតំណាងបំផុតនៃសហជីព, ប្រការ៦។
[៥០] ប្រកាសពីភាពជាតំណាងបំផុតនៃសហជីព, ប្រការ៥។
[៥១] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៥៧។

## ២.២.៤.អានុភាពនៃសេចក្តីបញ្ជាក់ភាពជាតំណាងបំផុតនៃសហជីព

សេចក្តីបញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពមិនអាចត្រូវប្តឹងតវ៉ាបានឡើយ ក្នុងរយៈពេល២(ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានភាពជាតំណាងបំផុត វៀរលែងតែក្នុងករណីដែលសហជីពមានភាពជាតំណាងបំផុត អាចបាត់បង់ភាពជាតំណាងបំផុតដោយមិនកំណត់ពេលវេលា ដូចខាងក្រោមនេះ ៖

១- នៅពេលដែលត្រូវបានរកឃើញថា សហជីពនោះបានខកខានបំពេញនូវករណីយកិច្ចជាទៀងទាត់របស់ខ្លួនដូចមានចែងក្នុងប្រការ១៣ នៃប្រកាសនេះ ដោយផ្អែកលើភស្តុតាងជាក់ស្តែង រួមទាំងការបដិសេធ ក្នុងការធ្វើជាតំណាងកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងអនុសញ្ញារួម។

២- នៅពេលដែលបញ្ជិការបស់សហជីពត្រូវបានលុប។

៣- នៅពេលដែលសហជីពត្រូវបានរំលាយ។

៤- នៅពេលណាដែលមានភស្តុតាងបញ្ជាក់ច្បាស់លាស់ថា សហជីពនោះលែងមានភាពជាតំណាងបំផុតទៀតហើយ។[52]

នៅពេលដែលភាពជាតំណាងបំផុតហួសរយៈពេល ២(ពីរ)ឆ្នាំ សហជីពណាមួយដែលមានវត្តមាន នៅក្នុងសហគ្រាស គ្រឹះស្ថានតែមួយជាមួយគ្នា ឬនៅក្នុងវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យជាមួយគ្នា អាចប្តឹងតវ៉ាទៅនឹងភាពជាតំណាងបំផុតនេះ តាមរយៈការស្វែងរកឱ្យមានការទទួលស្គាល់ដូចលក្ខណៈវិនិច្ឆ័យ ក្នុងប្រកាសនេះ។

រាល់បណ្តឹងតវ៉ាទៅនឹងភាពជាតំណាងបំផុត ត្រូវធ្វើទៅប្រធានអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជា តំណាងបំផុតដែលបានទទួលសំណុំបែបបទនោះ។ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត អាចចាត់ឱ្យមានការអង្កេត ប្រសិនបើចាំបាច់ត្រូវពិនិត្យឡើងវិញភាពជាតំណាងបំផុតរបស់សហជីពណាមួយ។ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត អាចព្យួរ ឬដកហូតភាពជាតំណាងបំផុតរបស់សហជីព ក្នុងករណីមានភស្តុតាងជាក់ច្បាស់ថាមានការរំលោភបំពាន ឬបាត់បង់លក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។

## ២.២.៥.សិទ្ធិ និងករណីយកិច្ចរបស់សហជីពដែលមានភាពជាតំណាងបំផុត

សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួម ដែលកើតចេញពី “ខ” ចែងទាំងឡាយ

---

៥២ ប្រកាសពីភាពជាតំណាងបំផុតនៃសហជីព, ប្រកាស១៥។

ក្នុងអនុសញ្ញារួម។ បន្ថែមលើសិទ្ធិទាំងឡាយដែលមានចែងក្នុងច្បាប់ស្តីពីសហជីព សហជីពដែលមានភាពជាតំណាងបំផុតមានករណីយកិច្ចដូចខាងក្រោម៖

- ចរចាដោយស្មោះត្រង់ជាមួយនិយោជកក្នុងគោលបំណងឱ្យមានការព្រមព្រៀងជាសមូហភាពទៅលើអនុសញ្ញារួមដែលផ្តោតទៅលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗទៀត
- ធ្វើជាតំណាងដោយស្មោះត្រង់ឱ្យកម្មករនិយោជិត ដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្តឹងតវ៉ាមិនសុខចិត្តដែលកើតចេញពីអនុសញ្ញារួម
- ធ្វើជាតំណាងដោយស្មោះត្រង់ឱ្យកម្មករនិយោជិតចំពោះវិវាទផ្សេងៗទៀត ដែលមិនកើតចេញពីអនុសញ្ញារួមតាមសំណើរបស់កម្មករនិយោជិត ឬសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស គ្រឹះស្ថាន
- មិនត្រូវរើសអើងនៅក្នុងពេលទទួលយកសមាជិកថ្មី
- បែងចែកអាសនៈនៅក្នុងយន្តការមួយចំនួនដែលបានកំណត់ក្នុងច្បាប់ស្តីពីការងារ។[៥៣]

## ២.២.៦.សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិច

សហជីពដែលមានសមាជិកភាគតិចទាំងឡាយនៅក្នុងសហគ្រាស គ្រឹះស្ថានដែលមានសហជីពមានភាពជាតំណាងបំផុតត្រូវបានបញ្ជាក់រួច ហើយដែលកំពុងស្ថិតនៅក្នុងសុពលភាពត្រូវបានហាមឃាត់លើការទាមទារ សិទ្ធិចរចាអនុសញ្ញារួម និងការទាមទារសិទ្ធិ ឬអត្ថប្រយោជន៍ផ្សេងៗដែលលើសពីអត្ថប្រយោជន៍ ចែងនៅក្នុងច្បាប់ បទបញ្ជា អនុសញ្ញារួមដែលកំពុងមានសុពលភាព ឬវិធានការងារផ្ទៃក្នុងទាំងឡាយ។

សិទ្ធិ និងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចរួមមាន ៖

ក- ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ។

ខ- ការផ្តល់ការប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន។

គ- ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទបុគ្គល។

ឃ-ការចូលរួមនៅក្នុងយន្តការកិច្ចសហការនៅកន្លែងការងារដែលប្រព្រឹត្តទៅជាប្រចាំ។

ង- ការចូលរួមប្រឹក្សាយោបល់នៅក្នុងយន្តការទីផ្សារការងារ។

ច- ការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន។

[៥៣] ប្រកាសពីភាពជាតំណាងបំផុតនៃសហជីព, ប្រកាស១៣។

ឆ- ការរៀបចំបង្កើតនូវសហករណ៍ដែលអាចជាហាងលក់ដូរតៅន់ អាហារដ្ឋាន ឬការថែរក្សាសុខភាព។ល។ សម្រាប់សម្រួលដល់ជីវភាពរស់នៅរបស់សមាជិកខ្លួន។

ជ- តួនាទីផ្នែករដ្ឋបាលនៅក្នុងការផ្ដល់ឱ្យនូវអត្ថប្រយោជន៍ដល់សមាជិករបស់ខ្លួនពេលគ្មានការងារធ្វើ។

ឈ-ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទការងាររួម ដែលមិនកើតចេញពីការអនុវត្តអនុញ្ញារួម។[៥៤]

## ២.២.៧.អនុសញ្ញារួម និងការដោះស្រាយវិវាទការងាររួម

ដូចដែលបានលើកឡើងខាងលើថា មានតែសហជីពតំណាងបំផុតទេ ដែលមានសិទ្ធិពិភាក្សាចងក្រងអនុសញ្ញារួមនេះបាន។[៥៥] ព្រោះថា ភាពជាតំណាងបំផុតរបស់សហជីព គឺមិនមែនតំណាងឱ្យតែសមាជិក នៃសហជីពរបស់ខ្លួននោះទេ គឺត្រូវតំណាងឱ្យទាំងកម្មករនិយោជិតដែលមិនមែនជាសមាជិករបស់ខ្លួនទៀតផង។[៥៦]

ម្យ៉ាងវិញទៀត អនុសញ្ញារួម គឺត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់អំពីលក្ខខណ្ឌការងារ លក្ខខណ្ឌមុខរបរ និងលក្ខខណ្ឌផ្សេងៗទៀត របស់កម្មករនិយោជិតនៃសហគ្រាស ឬគ្រឹះស្ថាននោះ។[៥៧]

ហើយអនុសញ្ញារួម ត្រូវបញ្ជាក់អំពីដែនអនុវត្តរបស់ខ្លួនដែលអាចមាន ៖

ក-ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ

- នៅថ្នាក់រោងជាង ឬការដ្ឋាន
- នៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន
- នៅថ្នាក់រាជធានីខេត្ត
- នៅថ្នាក់ជាតិ។

ខ-ក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ

- វិជ្ជាជីវៈមួយជាកំណត់
- វិជ្ជាជីវៈច្រើនបញ្ចូលរួមគ្នា ឬប្រហាក់ប្រហែលគ្នា
- សកម្មភាពសេដ្ឋកិច្ចមួយ ឬផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ចមួយជាកំណត់
- សកម្មភាពសេដ្ឋកិច្ចច្រើន ឬផ្នែកច្រើននៃសកម្មភាពសេដ្ឋកិច្ច។

[៥៤] ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសហជីព ឆ្នាំ២០២០, មាត្រា៥៩ថ្មី។
[៥៥] ច្បាប់ស្ដីពីសហជីព, មាត្រា៥៨។
[៥៦] ច្បាប់ស្ដីពីសហជីព, មាត្រា៥៨។
[៥៧] ច្បាប់ស្ដីពីសហជីព, មាត្រា៦៩។

គ-ក្នុងក្របខ័ណ្ឌវិស័យ

ឃ-ក្នុងក្របខ័ណ្ឌផ្លូវអាកាស និងផ្លូវសមុទ្រ។

ហើយបទប្បញ្ញត្តិនៃអនុសញ្ញារួមអាចនឹងមានលក្ខណៈប្រសើរ ដល់បុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ និងកម្មករនិយោជិត ជាងបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន។ ទោះជាយ៉ាងណាក៏ដោយ ក៏បទប្បញ្ញត្តិទាំងនេះមិនអាចផ្ទុយទៅនឹងបទប្បញ្ញត្តិស្តីពីសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមានទេ។ ការទាមទារទាំងអស់ ទាំងរបស់និយោជក ទាំងរបស់បុគ្គលិក ទាំងរបស់កម្មករនិយោជិតចំពោះសិទ្ធិអត្ថប្រយោជន៍នានា និងលក្ខខណ្ឌការងារដែលខុសពីច្បាប់ បទបញ្ជា និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ឬគ្រឹះស្ថានត្រូវដោះស្រាយតាមរយៈដំណើរការចរចាអនុសញ្ញារួមមួយដ៏ត្រឹមត្រូវ។ ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ក្របខ័ណ្ឌវិជ្ជាជីវៈ ក្របខ័ណ្ឌវិស័យ និងក្របខ័ណ្ឌផ្លូវអាកាស និងផ្លូវសមុទ្រ ត្រូវមានអនុសញ្ញារួមតែមួយប៉ុណ្ណោះ។

ភាគីនៃកិច្ចចរចាអនុសញ្ញារួមត្រូវតែទទួលបាននូវសិទ្ធិពេញលេញពីសមាជិករបស់ខ្លួន តាមរយៈការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬការប្រគល់សិទ្ធិដែលមានចែងក្នុងច្បាប់ស្តីពីសហជីព ដើម្បីធ្វើការ និងសម្រេចបានកិច្ចចរចា។ ការជ្រៀតជ្រែក ការញុះញង់ និងការរំខានពីបុគ្គលទាំងឡាយដែលមិនមានការពាក់ព័ន្ធនឹងអនុសញ្ញារួមត្រូវបានហាមឃាត់។[៥៨]

ក្រុមប្រឹក្សាចរចានៃសហជីព និងនិយោជកដែលត្រូវបានបង្កើតឡើង មានសិទ្ធិពេញលេញក្នុងនាមកម្មករនិយោជិតទាំងអស់ ឬនិយោជកទាំងអស់នៅគ្រប់កម្រិតថ្នាក់ចរចា ក្នុងករណីដែលត្រូវមាន ការចរចាចុះអនុសញ្ញារួមរវាងនិយោជកមួយ និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត ឬ រវាងនិយោជកច្រើន និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត។[៥៩]

សម្រាប់ការដោះស្រាយវិវាទការងាររួម សហជីពដែលមានភាពជាតំណាងបំផុត ត្រូវធ្វើការចរចាដោយស្មោះត្រង់ជាមួយនិយោជក ក្នុងគោលបំណងឈានទៅបង្កើតឱ្យបាននូវ ការព្រមព្រៀងជាសមូហភាពទៅលើអនុសញ្ញារួម ដែលផ្តោតទៅលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗទៀត។ ទន្ទឹមនឹងនេះដែរ ក៏ត្រូវធ្វើជាតំណាងដោយស្មោះត្រង់ឱ្យកម្មករនិយោជិត ដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្តឹងតវ៉ាមិនសុខចិត្តដែលកើតចេញពីអនុសញ្ញារួមនោះ ដែលបង្កើតបានទៅជាវិវាទការងាររួម។

ប៉ុន្តែក្នុងករណីដែលអនុសញ្ញារួមពុំបានចែងកំណត់អំពីនីតិវិធីសម្រាប់ការដោះស្រាយទេ ភាគីត្រូវជូនដំណឹងអំពីវិវាទការងាររួមទៅអធិការការងារនៃរាជធានី ខេត្តរបស់ខ្លួន។[៦០] បើតាមបញ្ញត្តិ នៃច្បាប់ស្តីពីការងារបាន

[៥៨] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៧១។

[៥៩] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា៧២។

[៦០] ច្បាប់ស្តីពីការងារ, មាត្រា៣០៣។

កំណត់ថា វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់នឹងបុគ្គលិករបស់ខ្លួនមួយចំនួនអំពីរឿងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយវិវាទនេះអាចបណ្ដាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម។[៦១]

ការដោះស្រាយវិវាទការងាររួម អាចធ្វើឡើងតាមវិធីផ្សះផ្សារ ប៉ុន្តែការផ្សះផ្សារនេះអាចធ្វើឡើងបានតែតាមសំណូមពររួម នៃភាគីវិវាទប៉ុណ្ណោះ។[៦២] ក្នុងករណីដែលការផ្សះផ្សារមិនអាចសម្រេចបញ្ចប់វិវាទបានទេ វិវាទអាចត្រូវបានប្ដឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលដើម្បីចាត់នីតិវិធីដោះស្រាយ។[៦៣]

[៦១] ច្បាប់ស្តីពីការងារ, មាត្រា៣០២។
[៦២] ច្បាប់ស្តីពីការងារ, មាត្រា៣០៥។
[៦៣] ច្បាប់ស្តីពីការងារ, មាត្រា៣០៩។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ
# ជុំវិញការអនុវត្តសិទ្ធិសហជីព
# នៅកម្ពុជា

# ជំពូកទី៣
# បញ្ហាប្រឈមនិងដំណោះស្រាយជុំវិញការអនុវត្តសិទ្ធិសហជីពនៅកម្ពុជា

សហជីពដែលបានចុះបញ្ជីតាមច្បាប់រួចហើយក៏ដោយក្តី ក៏មិនមែនមានន័យថា គេអាចអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ច បានដូចទៅនឹងគោលបំណងរបស់ច្បាប់ការងារ និងច្បាប់ស្តីពីសហជីពទាំងអស់នោះទេ។ ជាក់ស្តែងក្នុងច្បាប់ស្តីពីសហជីព ជំពូកទី៩(ការតំណាងដោយសហជីពដែលមានភាពជាតំណាងបំផុត) មាត្រា៥៥ កថាខណ្ឌ២, មាត្រា៥៨ និងមាត្រា៥៩ គឺសុទ្ធសឹងតែជាសិទ្ធិ និងកាតព្វកិច្ចចម្បងដែលអាចការពារនូវសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិតបាន ប៉ុន្តែសម្រាប់សហជីពធម្មតា(គ្មានភាពជាតំណាងបំផុត) ពុំអាចអនុវត្តសិទ្ធិ និងកាតព្វកិច្ចបានឡើយ។ មិនតែប៉ុណ្ណោះសូម្បីតែនៅគ្រឹះស្ថានខ្លះដែលមានចំនួនកម្មករនិយោជិតតិច ក៏គ្មានលទ្ធភាពក្នុងការបង្កើតឱ្យមាននូវសហជីពបានដែរ។

កត្តាទាំងនេះបានស្តែងឱ្យឃើញពីបញ្ហាប្រឈមមួយចំនួនចំពោះសហជីពកម្ពុជាក្នុងការអនុវត្តទៅតាមការកំណត់ទុកនៃច្បាប់ស្តីពីសហជីពដូចជា, បញ្ហប្រឈមរបស់សហជីពកម្ពុជា(៣.១)ក្នុងនោះរួមមាន៖ ការអនុវត្តច្បាប់ស្តីពីសហជីព (៣.១.១) និង ការខ្វះខាតនៃការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សហជីពក្នុងនាមជាអ្នកតំណាង (៣.១.២)។

## ៣.១.បញ្ហាប្រឈមរបស់សហជីពកម្ពុជា

### ៣.១.១. ការអនុវត្តច្បាប់ស្តីពីសហជីព

ក.ការកំណត់ចំនួនសមាជិកក្នុងការបង្កើតសហជីព

ដោយយោងទៅតាមច្បាប់ការងារ ឆ្នាំ១៩៩៧ ជំពូកទី១១ សេរីភាពសហជីព និងតំណាងកម្មករនិយោជិតនៅក្នុងសហគ្រាស បានចែងថា "**ដោយគ្មានការប្រកាន់អ្វីទាំងអស់ និងដោយពុំចាំបាច់មានការអនុញ្ញាតជាមុន កម្មករនិយោជិត និងនិយោជកមានសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈ តាមការជ្រើសរើសរបស់ខ្លួន** "។ ឯនៅក្នុងច្បាប់ស្តីពីសហជីពវិញ "**កម្មករនិយោជិត មានសិទ្ធិបង្កើត សហជីពនៅក្នុង ក្រុមហ៊ុនបានទាល់តែមានកម្មករនិយោជិតយ៉ាងតិចចំនួន ១០ នាក់ឡើងទៅ** "។[៦៤] ផ្អែកតាមពីរចំណុចលើនេះ ឃើញថាច្បាប់ស្តីពីសហជីពមានភាពផ្ទុយពីច្បាប់ការងារដែលជាបទប្បញ្ញត្តិដំបូងគេបង្អស់នៅកម្ពុជា បានចែងទាក់ទងនឹងសិទ្ធិ ក្នុងការបង្កើតសហជីព។ ការកំណត់ពីចំនួននៃការបង្កើតនេះផងដែរ បានរឹតត្បិតជាខ្លាំងនូវសិទ្ធិក្នុងការបង្កើតសហជីពពីព្រោះថា ទាល់តែមានសមាជិកគ្រប់ទៅតាមចំនួនកំណត់ខាងលើទើបច្បាប់ ទទួលស្គាល់ថាអាចបង្កើតបាន។

[៦៤] ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦, មាត្រា១០។

យ៉ាងណាមិញ បើក្រឡេកទៅមើលអនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគមវិញបានកំណត់យ៉ាងច្បាស់ថា កម្មករនិយោជិត មានសិទ្ធិក្នុងការបង្កើតសមាគម លើកលែងតែការគោរពបទបញ្ជាផ្ទៃក្នុងនៃអង្គការសាមីចេញ តែទោះជាយ៉ាងណាក៏ នៅមានសិទ្ធិចូលរួមក្នុងសមាគមតាមការជ្រើសរើសរបស់ខ្លួន និងដោយមិនចាំបាច់មានការអនុញ្ញាតជាមុនឡើយ។ ក្នុងនោះ សមាជិកនីមួយៗនៃអង្គការអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះ គឺត្រូវតែទទួលខុសត្រូវឱ្យមានប្រសិទ្ធិភាពនូវបទប្បញ្ញត្តិទាំងឡាយណាដែល បានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ៉។ បើបែបនេះតើការបង្កើតសហជីពនៃច្បាប់ស្តីពីសហជីពនោះផ្ទុយទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មែនដែរឬទេ? ហើយនេះជាចំណុចនៃគំនិតដែលគួរតែពិចារណា។

ខ. លក្ខណៈតឹងរ៉ឹងនិងស្មុគស្មាញក្នុងការចុះបញ្ជី

ថ្វីបើមានការលើកឡើងនូវលក្ខខណ្ឌចាំបាច់តាមច្បាប់ការងារច្រើនដង ថាសហជីពអាចត្រូវ បានបង្កើតឡើងដោយពុំចាំបាច់មានការអនុញ្ញាតជាមុនក៏ដោយ ក៏ច្បាប់ស្តីពីសហជីពបានបញ្ញត្តិ យ៉ាងតឹងរ៉ឹង ជាមួយនឹងលក្ខខណ្ឌតម្រូវជាច្រើនដែលត្រូវបំពេញ មុនពេលសហជីពអាចទទួលបាន នូវការយល់ព្រមឱ្យចុះបញ្ជីពីក្រសួងការងារ។

ចំពោះលក្ខខណ្ឌ តម្រូវសម្រាប់ការស្នើសុំចុះបញ្ជីតម្រូវឱ្យមាននូវ ៖

- ច្បាប់ដើមលក្ខន្តិកៈរបស់សហជីពរាប់បញ្ចូលសេចក្តីថ្លែងការណ៍ស្តីពីគោលបំណងខ្លួន
- ច្បាប់ដើមនៃបទបញ្ជាផ្ទៃករដ្ឋបាល ដែលគ្រប់គ្រងទៅលើការដឹកនាំ និងកិច្ចការរដ្ឋបាល
- បញ្ជីរាយនាមនៃអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព
- សៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាហិរញ្ញវត្ថុ
- កំណត់ហេតុច្បាប់ដើម នៃការបោះឆ្នោតបង្កើតអង្គការវិជ្ជាជីវៈ(សហជីព)ជាអាទិ៍។

ដោយសារតែកម្មករនិយោជិតភាគច្រើន(ពិសេសនៅតាមសហគ្រាស ឬរោងចក្រជាអាទិ៍) ពួកគេពុំអាចយល់ដឹងច្បាស់ថា**តើឯកសារដែលបានរៀបរាប់ខាងលើគឺជាអ្វី?**[៦៥] ហើយនេះគឺជាហេតុបង្កឱ្យមានផលវិបាក

[៦៥] ការលើកឡើងរបស់លោក អាត់ ធន់ ជាប្រធានសហភាពការងារកម្ពុជា (Cambodia Labour Confederation) បានផ្តល់កិច្ចសម្ភាសដល់សិក្ខាកាម Newsroom Cambodia អំពីបញ្ហាប្រឈមរបស់តំណាងសហជីពនៅក្នុងកន្លែងការងារ ថ្ងៃទី៦ ខែ វិច្ឆិកា ឆ្នាំ២០២២។ https://newsroomcambodia.com/news/២០២២/១១/១៦/qa%E១%៩F%៩៦-%E១%៩E%៨0%E១%៩E%B៦%E១%៩E%៩A%E១%៩E%៩៤%E១%៩E%៨៤%E១%៩F%៩២%E១%៩E%៨0%E១%៩E%BE%E១%៩E%៨F%E១%៩E%៩F%E១%៩E%A0%E១%៩E%៨៧%E១%៩E%B៨%E១%៩E%៩៦%E១%៩E%៩៣%E១%៩F%៨៥/

ដល់សហជីពក្នុងការចុះបញ្ជីផងដែរ។ ព្រោះថាសហជីពត្រូវបានបោះឆ្នោត និងជ្រើសរើសចេញពីកម្មករនិយោជិត។[៦៦] ជាមួយនេះដែរ បើយោងតាមសលាកបត្រព័ត៌មានដែលចេញដោយអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីអំពី ច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ដោយបានចាត់ចំណាត់ថ្នាក់ច្បាប់ស្តីពីសហជីពនៅកម្រិតពណ៌ក្រហម និងអះអាងថាច្បាប់ស្តីពីសហជីពបានចែងពីលក្ខខណ្ឌតម្រូវខ្លាំងពេក សម្រាប់ការចុះបញ្ជីដែលរឹតត្បិតដោយពុំត្រឹមត្រូវ ទៅលើលទ្ធភាពរបស់សហជីពក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ។

ការកំណត់ទាំងនេះបានធ្វើឱ្យកម្មករនិយោជិត មានការលំបាកជាខ្លាំងដើម្បីបង្កើតបាន នូវអង្គការសហជីពក៏ដូចជាដើម្បីក្លាយខ្លួនជាសមាជិកសហជីពស្របច្បាប់មួយ។ ប្រសិនបើធ្វើការប្រៀបធៀបទិន្នន័យសរុបរបស់សហជីពដែលបានចុះបញ្ជីរួចរបស់កម្ពុជាជាមួយប្រទេសដទៃទៀត យើងសង្កេតឃើញថា កម្ពុជាមានចំនួនសហជីពត្រឹម ៦២៧២តែប៉ុណ្ណោះ(គិតត្រឹមឆ្នាំ២០២៣)[៦៧] ប្រទេសជប៉ុនមានចំនួន ២២ ៧៨៩ សហជីព(គិតត្រឹមឆ្នាំ២០២៣)[៦៨] និង ប្រទេសវៀតណាមមានចំនួន ១២២ ០០០ សហជីព(គិតត្រឹមឆ្នាំ២០២៣)[៦៩] តាមទិន្នន័យខាងលើបានបង្ហាញឱ្យឃើញថាចំនួនសហជីពដែលបានចុះបញ្ជីរួចនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចនៅឡើយ បើធៀបនឹងប្រទេសដែលបានលើកឡើងខាងលើ។

មិនតែប៉ុណ្ណោះតាមរយៈការចុះផ្សាយព័ត៌មានរបស់គេហទំព័រVOA កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ បានបង្ហាញថា ក្រុមសហជីពមួយចំនួននៅតែបន្តលើកឡើងថាខ្លួនពិបាកក្នុងការចងក្រងសហជីពនៅតាមរោងចក្រ និងកន្លែងផ្សេងទៀត។ ហើយនោះក៏ជាហេតុនាំឱ្យសេរីភាពសហជីពនៅកម្ពុជាកាន់តែធ្លាក់ចុះជាខ្លាំង។[៧០]

---

[៦៦] ច្បាប់ការងារ ឆ្នាំ១៩៩៧, មាត្រា២៦៩។

[៦៧] ពិធីបិទសន្និបាតបូកសរុបការងារ ឆ្នាំ២០២៣ https://www.youtube.com/live/RniZDM១s៧២A?si=៥JYOrqvKinJ១mmm៨

[៦៨] ទិដ្ឋភាពទូទៅនៃការស្ទង់មតិមូលដ្ឋានសហជីពការងារឆ្នាំ ២០២៣ របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពជប៉ុន
厚生労働省「令和 ៥ 年労働組合基礎調査の概況」៣ 頁
https://www.mhlw.go.jp/toukei/itiran/roudou/roushi/kiso/២៣/dl/gaikyou.pdf

[៦៩] Japan International labor foundation , ឯកសារសរុបទិន្នន័យរបស់សហព័ន្ធការងារវៀតណាម(VGCL)
（公益財団法人国際労働財団、ベトナム労働総同盟の合計データのレポート(VGCL) ）
https://www.jilaf.or.jp/nc_view/nc_view-១៣៦១/

[៧០] មេដឹកនាំសហជីព៖ ការបង្កើតសហជីពឯករាជ្យកំពុងស្ថិតក្រោមការរឹតត្បិត និងប្រឈមការរើសអើងកាន់តែខ្លាំង
https://khmer.voanews.com/a/union-leaders-say-after-the-amendment-of-labor-laws-the-formation-of-independent-unions-is-under-restriction-and-faces-discrimination/៧១៦០០៥១.html

### ៣.១.២.ការខ្វះខាតនៃការអនុវត្តសិទ្ធិ និងភាតព្វកិច្ចរបស់សហជីពក្នុងនាមជាអ្នកតំណាង

ក្នុងនាមជាសហជីពក្រៅពីការការពារសិទ្ធិជូនកម្មករ គេក៏មានតួនាទីក្នុងការដោះស្រាយវិវាទការងាររួម និងការចរចាអនុសញ្ញារួមផងដែរ។ កាលណាមានសហជីព នោះសហជីពនឹងដើរតួរ ជាអ្នកតំណាងឱ្យកម្មករនិយោជិត រាល់ពេលមានវិវាទរួមកើតឡើងដើម្បីទៅចរចា ជាមួយភាគីនិយោជកដែលជាដៃគូវិវាទ ឬក៏ទៅធ្វើការទាមទារក្នុងនាមជាអ្នកតំណាងចំពោះមុខស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធនឹងការដោះស្រាយវិវាទការងារនោះ។

ប៉ុន្តែដោយសារតែ សហជីពត្រូវបានបោះឆ្នោត និងជ្រើសរើស ចេញពីកម្មករនិយោជិត ហើយកម្មករនិយោជិតមួយចំនួនធំ (ជាពិសេសកម្មករនិយោជិត នៅតាមសហគ្រាស ឬរោងចក្រ) ពុំបានបញ្ចប់ការសិក្សាបានពេញលេញនោះទេ ដោយពួកគេបានបោះបង់ការសិក្សា និងចេញមករកការងារធ្វើដើម្បីផ្គត់ផ្គង់ជីវភាព ដែលជាហេតុនាំឱ្យការយល់ដឹងរបស់គាត់នៅមានកម្រិតនៅឡើយ។[៧១] យោងតាមរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភាឆ្នាំ២០១៨~២០២២ ត្រង់ចំណុចនៃគុណភាពនៃវិស័យអប់រំមានបង្ហាញឱ្យឃើញថា សិស្សដែលបានបានបោះបង់ការសិក្សា និងចេញមករកការងារធ្វើមានចំនួនច្រើន។[៧២] ដោយសារតែបែបនេះហើយទើប ក្រសួងអប់រំយុវជននិងកីឡា និងអង្គការយូណេស្កូបានបង្កើតកម្មវិធីអក្ខរកម្ម ដើម្បីជួយឱ្យកម្មករនិយោជិតធ្វើការនៅតាមរោងចក្រនានា ទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈជាមូលដ្ឋាននិងអាចបន្តការសិក្សាបាន។ ដោយកម្មករនិយោជិតដែលបានចូលរួមសិក្សាក្នុងកម្មវិធីនេះនឹងទទួលបានសញ្ញាបត្រមធម្យមសិក្សាត្រឹមបឋមភូមិក្រោយបញ្ចប់ការសិក្សា។ ទោះបីជាយ៉ាងនេះក្តី កាលដែលក្លាយទៅជាសហជីព ដែលមានភារកិច្ចការពារសិទ្ធិនិង ផលប្រយោជន៍ជូនកម្មករ គេក៏មានតួនាទីក្នុងការតំណាងឱ្យកម្មករនិយោជិតក្នុង ការដោះស្រាយវិវាទការងារ និងការចរចាអនុសញ្ញារួមជាអាទិ៍ផងដែរ។ ចុះបើពួកគេមិនទាន់មានចំណេះដឹង គ្រប់គ្រាន់នៅឡើយ

---

[៧១] ដោយសារតែបន្ទុកនិងកាតព្វកិច្ចទទួលខុសត្រូវចំពោះគ្រួសារ សេដ្ឋកិច្ច និងសង្គម ស្ត្រីធ្វើការនៅតាមរោងចក្រជាច្រើននៅក្នុងប្រទេសកម្ពុជា បានបោះបង់ចោលឱកាសអប់រំជាមូលដ្ឋាន ឬមិនមានឱកាសចូលរៀន។ ហើយកម្មវិធីអក្ខរកម្មនេះបង្កើតឡើងសម្រាប់កម្មករកម្មការិនីតាមរោងចក្រ ឱ្យចេះអាន សរសេរ និងចេះគិតលេខជាដើម https://vayofm.com/news/detail/១៣០៨២៨-៦៩៩.html (បានចូលមើលចុងក្រោយ ២ កញ្ញា ២០២៤)។

[៧២] ដោយសិស្សដែលបានបញ្ចប់ត្រឹមថ្នាក់បឋមមានប្រមាណ២ ១៦៧ ១៥២នាក់ រីឯសិស្សដែលបានបញ្ចប់ដល់ថ្នាក់ទុតិយភូមិមានប្រមាណ ៧២០៦៤នាក់តែប៉ុណ្ណោះ។ (របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភាឆ្នាំ២០១៨~២០២២ https://pressocm.gov.kh/wp-content/uploads/២០២៣/០៦/Brief-report-main-achievements-of-the-implementation-of-the-Rectangular-Strategy-Phase-៤.pdf(បានចូលមើលចុងក្រោយ ២ សីហា ២០២៤)។

តើពួកគេអាចអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់បានយ៉ាងដូចម្ដេច? ជាឧទាហរណ៍ ក្នុងមាត្រា៥៨ ចំណុចទី១នៃច្បាប់ស្ដីពីសហជីព បានកំណត់ថាសហជីពមានកាតព្វកិច្ចក្នុង ការចរចាជាសមូហភាពសម្រាប់បង្កើតអនុសញ្ញារួមជាអាទិ៍ និងក្នុងមាត្រា៥៩ ចំណុច ក.ស្ដីពីការផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ, ចំណុច ខ. ស្ដីពីការផ្ដល់ប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្ដែងដល់សមាជិករបស់ខ្លួន, ចំណុច គ. ស្ដីពីការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទបុគ្គល នៃច្បាប់ស្ដីពីសហជីពជាអាទិ៍។ ព្រោះថាចំណុចមួយចំនួន នៃមាត្រាខាងលើ គឺទាមទារឱ្យសហជីពយ៉ាងហោចណាស់ មានចំណេះដឹងមូលដ្ឋានផ្នែកច្បាប់ការងារដែរ ទើបអាចអនុវត្តតួនាទី ភារកិច្ចទាំងនោះបាន។ មិនតែប៉ុណ្ណោះ តាមរយៈការលើកឡើងរបស់ លោក ឈាវ វ៉ៅ ក្នុងកម្មវិធី ថៅកែល្អ កម្មករល្អថា អនុសញ្ញារួមនាពេលបច្ចុប្បន្នគឺនៅមានតិចនៅឡើយ ដែលអាចមានន័យថា សហជីពដែលជាតំណាងបំផុតនៅកម្ពុជា នៅមានតិច ឬសហជីពតំណាងបំផុតមិនដឹងពីអនុសញ្ញារួមនេះ។[៧៣]

ជាឧទាហរណ៍ យោងតាមការដោះស្រាយវិវាទការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺមានច្រើនទាក់ទងទៅនឹងការទាមទារដែលគ្មានក្នុងកិច្ចសន្យា ឬផ្ទុយទៅនឹងច្បាប់ការងារ។ ករណីជាក់ស្ដែង នៃការបំពេញភារកិច្ចរបស់សហជីពដែលមានជាតំណាងបំផុតក្នុងការដោះស្រាយវិវាទការងាររួម មាននៅក្នុងករណីសិក្សានៃសេចក្ដីបង្គាប់ ០២០/២៣- ហ៊ុយ ស៊ិនទូ (ខេមបូឌា) ហ្វេសិន ខូអិលធីឌី ដូចខាងក្រោម[៧៤]៖

> ហ៊ុយ ស៊ិនទូ (ខេមបូឌា) ហ្វេសិន ខូអិលធីឌី (រោងចក្រកាត់ដេរ) លេខ ០២០/២៣ តំណាងសហជីពបានទាមទារឱ្យ និយោជកនៅតែរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗសម្រាប់កម្មករចំនួន ៣០៩នាក់ ដែលធ្វើកូដកម្មនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

---

[៧៣] កម្មវិធីវិទ្យុ (ថៅកែល្អ កម្មករល្អ) ប្រធានបទ៖ អនុសញ្ញារួម
https://wmc.org.kh/previous-program/%E១%៩E%៩០%E១%៩F%៨៥%E១%៩E%៨០%E១%៩F%៨២%E១%៩E%៩B%E១%៩F%៩២%E១%៩E%A២%E១%៩E%៨០%E១%៩E%៩៨%E១%៩F%៩២%E១%៩E%៩៨%E១%៩E%៨០%E១%៩E%៩A%E១%៩E%៩B%E១%៩F%៩២%E១%៩E%A២-%E១%៩E%៨០%E១%៩E%៩៨%E១%៩F%៩២%E១%៩E%៩៨%E១%៩E%៩C%E១%៩E%B៧/ (បានចូលមើលចុងក្រោយ ២ សីហា ២០២៤)។

[៧៤]លេខ និង ឈ្មោះសំណុំរឿង ៖ ០២០/២៣-ហួយ ស៊ីន ទូ (ខេមបូឌា) ហ្វេសិន ឯ.ក
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣
https://www.arbitrationcouncil.org/download/%e១%៩f%a០%e១%៩f%a២%e១%៩f%a០-%e១%៩f%a២%e១%៩f%a៣-%e១%៩e%a០%e១%៩e%bd%e១%៩e%៩៩-%e១%៩e%៩f%e១%៩e%bb%e១%៩e%b៨%e១%៩e%៩៣-%e១%៩e%៩១%e១%៩e%bc-%e១%៩e%៨១%e១%៩f%៨១%e១%៩e%៩៨%e១%៩e%៩៤%e១%៩e%bc%e១%៩e%៨c%e១%៩e%b៦/?lang=km&wpdmdl=១៤៧៨៨&refresh=៦៦d៥ddcfa០៩៥f១៧២៥២៩១៩៨៣(បានចូលមើលចុងក្រោយ ២ សីហា ២០២៤)។

តែតាមមាត្រា ៣២៤ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "ការធ្វើកូដកម្ម ត្រូវជូនដំណឹងមុនក្នុងរយៈពេលយ៉ាងតិចប្រាំពីរថ្ងៃ គិតតែថ្ងៃធ្វើការ ហើយត្រូវតម្កល់ទុកនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។..." កថាខណ្ឌទី៤ មាត្រា ៣២០ នៃច្បាប់ស្តីពីការងារ ដដែលចែងថា ៖ "សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបាន លុះត្រាតែបានប្រើប្រាស់អស់ លទ្ធភាពក្នុងការដោះស្រាយ ជម្លោះដោយមធ្យោបាយសន្តិវិធីជាមួយនិយោជក។

លើសពីនេះ កថាខណ្ឌទី១ មាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "កិច្ចសន្យាការងារ ត្រូវព្យួរនៅពេលធ្វើកូដកម្ម។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ"។

ចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ ដដែលចែងថា ៖ "ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់ ចំពោះតែកាតព្វកិច្ចសំខាន់ៗ នៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទបញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត"។

ហេតុនេះហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារបានបដិសេធការទាមទារនោះ។ មូលហេតុគឺកូដកម្មនេះជាកូដកម្មមិនគោរពច្បាប់ការងារ ដូច្នេះកម្មករដែលចូលរួមក្នុងកូដកម្មមិនគោរពច្បាប់ការងារពុំមានសិទ្ធិទទួលបានប្រាក់ឈ្នួល ឬប្រាក់បន្ថែមធម្មតាឡើយ។[៧៥]

តាមរយៈករណីសិក្សាខាងលើនេះបានបង្ហាញឱ្យដឹងថា កម្រិតក្នុងការយល់ដឹងផ្នែកច្បាប់ការងាររបស់សហជីពគឺនៅមានកម្រិតនៅឡើយ។ ព្រោះថាតាមការទាមទាររបស់សហជីពក្នុងករណីសិក្សាខាងលើ គេអាចមិនដឹងពីលក្ខខណ្ឌជុំវិញការធ្វើកូដកម្មស្របច្បាប់ និងទំហំនៃសិទ្ធិរបស់ខ្លួនជុំវិញការធ្វើកូដកម្មនេះ។

## ៣.២.ដំណោះស្រាយ

### ៣.២.១.ចំពោះការកំណត់ចំនួនសមាជិកក្នុងការបង្កើតសហជីព និង នីតិវិធីក្នុងការចុះបញ្ជី

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយមិនមានការប្រកាន់អ្វីទាំងអស់។ បន្ថែមលើនេះគួរគប្បីឱ្យកម្មករនិយោជិតទាំងអស់ មិនថាកំពុងបម្រើការក្នុងគ្រឹះស្ថាន ដែលមានចំនួនកម្មករនិយោជិតតិចក៏ដោយ ក៏ពួកគេគួរតែទទួលបានសិទ្ធិ ក្នុងការឈរឈ្មោះសម្រាប់ការបោះឆ្នោត ជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រង

[៧៥] ក្រុមប្រឹក្សាអាជ្ញាកណ្តាល, "អ្វីទៅជាភាពខុសគ្នារវាងវិវាទអំពីសិទ្ធិ និងវិវាទអំពីផលប្រយោជន៍?", ២៦ សីហា ២០១៩, https://www.arbitrationcouncil.org/right-vs-interests-disputes-whats-the-difference/ (ចូលមើលចុងក្រោយ ២៩ សីហា ២០២៤)។

សហជីពផងដែរ។ នេះជាមូលដ្ឋានគតិយុត្តដ៏រឹងមាំសម្រាប់ស្ថាប័នមានសមត្ថកិច្ច ពិសេសក្រសួងទទួលបន្ទុកវិស័យការងារត្រូវតែចាត់វិធានការ និងដាក់ចេញនូវយន្តការត្រួតពិនិត្យនានា ដើម្បីធានាថាបញ្ញត្តិនេះត្រូវបានអនុវត្តយ៉ាងពេញលេញ និងស្មើភាពចំពោះគ្រប់ភាគី ពិសេសធ្វើយ៉ាងណាបង្កលក្ខណៈងាយស្រួលដល់កម្មករនិយោជិត ដែលមានបំណងចង់លើកកម្ពស់សិទ្ធិ និងការពារផលប្រយោជន៍របស់ពួកគេពីការកេងប្រវ័ញ្ចមកលើកម្មករនិយោជិត ដែលគ្មានអ្វីជាទីពឹងក្រៅពីសហជីព ដែលជាតំណាងរបស់ពួកគាត់ ដែលដឹងសុខទុក្ខរបស់ពួកគាត់នៅកន្លែងធ្វើការ និងអាចដោះស្រាយបញ្ហាបានឆាប់រហ័សជាងផងដែរ។ បើយើងក្រឡេកទៅមើលទិដ្ឋភាពនៃប្រព័ន្ធសហជីពរបស់ប្រទេសវៀតណាម និងជប៉ុនវិញនោះ នៅក្នុងប្រទេសវៀតណាម សហជីពនិងត្រូវបានបង្កើតឡើង ដោយមាន**កម្មករនិយោជិតយ៉ាងតិចចំនួន ៥ នាក់ឡើងទៅ**តែប៉ុណ្ណោះ[៧៦] និងប្រទេសជប៉ុន សហជីព នឹងត្រូវបានបង្កើតឡើង ដោយមាន**កម្មករនិយោជិតយ៉ាងតិចចំនួន ២ នាក់ឡើងទៅ**តែប៉ុណ្ណោះ។[៧៧] បែបនេះគឺមានន័យថា ការបង្កើតសហជីពរបស់គេពុំមានភាពតឹងរ៉ឹង ថែមទាំងងាយស្រួលដល់កម្មករនិយោជិត ក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្លួនបាន។

ម្យ៉ាងទៀតចំពោះបញ្ហាក្នុងការចុះបញ្ជីសហជីព ក្រសួងពាក់ព័ន្ធគួរចាត់វិធានការណែនាំ ឬ បង្ហាត់បង្ហាញដល់សហជីពថ្មីថ្មោងដែលនឹងរៀបធ្វើការចុះបញ្ជី ឱ្យស្គាល់ និងដឹងពីឯកសារសំខាន់ៗ សម្រាប់ធ្វើការចុះបញ្ជីឱ្យបានត្រឹមត្រូវ ឬបង្កើតជាតារាងគំរូនៃសំណុំឯកសារសំខាន់ៗទាំងឡាយ ដែលបង្កជាភាពងាយស្រួលដល់ការចុះបញ្ជីសហជីព ឬបង្កើតជាការចុះបញ្ជីតាមបែបឌីជីថល ដែលជាមធ្យោបាយថ្មី និងងាយស្រួលក្នុងការចុះបញ្ជីសហជីពផងដែរ។

### ៣.២.២.លើកកម្ពស់យន្តការពិគ្រោះយោបល់ និងការអប់រំច្បាប់

ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលព័ត៌មាន និងស្តាប់នូវកង្វល់ បញ្ហាប្រឈម ក៏ដូចជាសំណើសំណូមពរ គឺជាជម្រើសដ៏ល្អបំផុតក្នុងការដោះស្រាយវិវាទ។ ជាក់ស្តែងនៅប្រទេសជប៉ុន ដោយសារតែសហជីពពុំមានសមត្ថភាពផ្នែកច្បាប់គ្រប់គ្រាន់ រាល់ពេលមានវិវាទកើតឡើងគេតែងធ្វើការពិភាក្សា ពិគ្រោះយោបល់ជាមួយមេធាវី វិស័យការងារមិនថាជាការប្រឹក្សាតាមរយៈទូរស័ព្ទដៃ, តាមរយៈគេហទំព័ររបស់ក្រុមហ៊ុន

[៧៦] ការរួមបញ្ចូលរបស់សហជីពកម្មករនិយោជិតវៀតណាម មាត្រា ១៦
https://www.i-glocal.com/report/១៣៧/ (បានចូលមើល ចុងក្រោយ ២៩ សីហា ២០២៤)។

[៧៧]សហព័ន្ធសហជីពជប៉ុន Shiga,ការបង្កើតសហជីព
(日本労働組合連合会滋賀, 労働組合の作り方)
https://rengo-shiga.jp/soudan/union-how-to-make(បានចូលមើល ចុងក្រោយ ៣០ សីហា ២០២៤)។

មេធាវីជាអាទិ៍ ដើម្បីអាចប្រាកដថា ការទាមទាររបស់ពួកគេអាចទទួលបាននូវលទ្ធផលល្អ និងចំណេញពេលវេលា។[78]

ដូចដឹងស្រាប់ហើយថា ច្បាប់ត្រូវបានតាក់តែងឡើងដើម្បីគ្រប់គ្រងសកម្មភាពសង្គមឱ្យប្រព្រឹត្តទៅជាប្រក្រតី រក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងភាពសុខដុមរមនា ហើយច្បាប់តែងមានការប្រែប្រួលទៅតាម ការវិវត្តន៍នៃសង្គមផងដែរ។ ដូច្នេះ តាមរយៈយន្តការពិគ្រោះយោបល់ រាជរដ្ឋាភិបាលដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការលើវិស័យការងារនេះ នឹងទទួលបាននូវកង្វល់ការលំបាកក្នុងការអនុវត្តច្បាប់ស្តីពីសហជីពដើម្បីជាមូលដ្ឋានក្នុងការដាក់បញ្ចូលទៅក្នុងការធ្វើវិសោធនកម្មលើកក្រោយៗទៀត សំដៅធ្វើយ៉ាងណាសម្របសម្រួលការអនុវត្តសិទ្ធិសហជីពរបស់កម្មករនិយោជិត ឱ្យស្របតាមគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ។

ជាមួយគ្នានេះ ភាគីពាក់ព័ន្ធរួមមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហជីព សង្គមស៊ីវិលចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ សិទ្ធិសហជីព និងសិទ្ធិកម្មករនិយោជិត តាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំនានា។ ការជួបជុំបណ្តុះបណ្តាល ជាគន្លឹះយ៉ាងសំខាន់ក្នុងការណែនាំពន្យល់ឱ្យបានក្បោះក្បាយលម្អិតទៅលើច្បាប់ ពីព្រោះថាការខ្វះចំណេះដឹងផ្នែកច្បាប់ ឬខកខានមិនបានពន្យល់ឱ្យស៊ីជម្រៅ វាងាយនឹងកើតឡើង នូវការយល់ខុស ដែលនាំឱ្យការអនុវត្តច្បាប់ស្តីពីសហជីពរវាងក្រសួងជាសេនាធិការ និងអង្គការវិជ្ជាជីវៈ មិនស៊ីសង្វាក់គ្នា។

[៧៨] យ៉ូជីរូ មីស៊ុម៉ាជី,នីតិកាងារ(ជប៉ុន៖រោងបោះពុម្ពយូហ៊ីកាគី,បោះពុម្ពលើកទី៧ ឆ្នាំ២០១៨)៣៨៧-៣៨៨
( 水町勇一郎、『労働法』（有斐閣、第７版、២០១៨ 年）៣៨៧－៣៨៨ 頁។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវលើប្រធានបទ "**សិទ្ធិរបស់សហជីពនៅកម្ពុជា**" រួចមកយើងឃើញថា ការប្រកាសដាក់ឱ្យប្រើច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ជាការលើកកម្ពស់សិទ្ធិក្នុងការបង្កើតសហជីព ដែលត្រូវបានធានា និងការពារដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ព្រោះថាអង្គការវិជ្ជាជីវៈមួយនេះបានបង្កើតឱ្យមានការការពារ និងលើកតម្កើងផលប្រយោជន៍កម្មករនិយោជិត ស្របតាមផ្លូវច្បាប់។

ការបង្កើតនូវបុគ្គលភាពគតិយុត្តនេះ ទៀតសោតគឺបានផ្តល់ឱកាសឱ្យសហជីពធ្វើជាតំណាងឱ្យកម្មករនិយោជិតដែលជាសមាជិករបស់ខ្លួនក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់កម្មករនិយោជិត តាមរយៈការប្រើប្រាស់នូវសិទ្ធិរបស់សហជីពដូចជា សិទ្ធិក្នុងការពិគ្រោះគ្នាជាមួយនិយោជកដោយសេរីក្នុងគោលដៅលើកតម្កើង និងការពារផលប្រយោជន៍ខាងផ្នែកស្មារតី និងសម្ភារដល់សមាជិករបស់ខ្លួន ពិគ្រោះពិភាក្សាលើសេចក្តីព្រាង ឬកែសម្រួលបទបញ្ជាផ្ទៃក្នុង និងពិគ្រោះពិភាក្សាជុំវិញ ការមានបំណងបញ្ឈប់កម្មករនិយោជិតដោយសារមូលហេតុផ្សេងៗ ក៏ដូចជាចងក្រងបង្កើតអនុសញ្ញារួម ដែលមានចរិតលក្ខណៈដូចទៅនឹងច្បាប់តូចមួយសម្រាប់អនុវត្តក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។

ប៉ុន្តែទន្ទឹមនឹងមានការលើកកម្ពស់សហជីពបែបនេះ បញ្ហាប្រឈមជាច្រើនក្នុងការអនុវត្តច្បាប់ស្តីពីសហជីពក៏កើតមានឡើងផងដែរ។ បញ្ហាដែលជួបប្រទះជារឿយៗដោយទី១ គឺការកំណត់ចំនួនសមាជិក ក្នុងការបង្កើតសហជីព ដែលភាគច្រើន កម្មករនិយោជិតយល់ថាជាការរើសអើង ហើយបញ្ហានេះ បានផ្តល់សម្ពាធយ៉ាងខ្លាំងដល់កម្មករនិយោជិត ដែលបម្រើការនៅគ្រឹះស្ថានដែលមានកម្មករនិយោជិតតិច ព្រោះថា ពួកគេមិនអាចអនុវត្តនូវសិទ្ធិ ដូចទៅនឹងកម្មករ ដែលបម្រើការនៅសហគ្រាស ឬគ្រឹះស្ថានដែលមានកម្មករនិយោជិតច្រើននោះទេ។ បញ្ហាទីពីរ គឺនីតិវិធីចុះបញ្ជីសហជីព គឺចាប់តាំងពីការបង្កើតច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ សហជីពដែលត្រូវបានឃ្លាំមើលដោយអង្គការសង្គមស៊ីវិលបានត្អូញត្អែរពីផលលំបាកនៅក្នុងនីតិវិធីចុះបញ្ជីថាមានភាពស្មុគស្មាញ។ រហូតដល់មានការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីព កាលពីឆ្នាំ២០២០ ក៏នៅតែមិនបានបន្ធូរបន្ថយលក្ខខណ្ឌណាមួយនៃការចុះបញ្ជីដែលដាក់បន្ទុកចំពោះសហជីពទេ។ នោះនឹងមានន័យថាការចុះបញ្ជីនៅតែជាឧបសគ្គមួយរបស់សហជីព។ ជាមួយនេះដែរ បើយោងតាមសលាកបត្រព័ត៌មាន ដែលចេញដោយ អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីអំពី ច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ ដោយបានចាត់ចំណាត់ថ្នាក់ច្បាប់ស្តីពីសហជីព គឺនៅកម្រិតពណ៌ក្រហម និងអះអាងថាច្បាប់ស្តីពីសហជីពបានចែងពីលក្ខខណ្ឌតម្រូវខ្លាំងពេក សម្រាប់ការចុះបញ្ជីដែលរឹតត្បិតដោយពុំត្រឹមត្រូវ ទៅលើលទ្ធភាពរបស់សហជីពក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ។ តែទោះជាយ៉ាងនេះក្តី ភាគីរាជរដ្ឋាភិបាលនៅតែប្រកាន់ជំហរថាច្បាប់ស្តីពីសហជីព ដែលបានតាក់តែងឡើង ដោយផ្អែកលើ

រដ្ឋធម្មនុញ្ញកម្ពុជា និងស្របតាម អនុសញ្ញារបស់អង្គការ ILO ហើយស្របទៅតាមបទដ្ឋានអន្តរជាតិ ក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ របស់កម្មករនិយោជិត និងធានានូវសិទ្ធិសេរីភាពរបស់សហជីព។ បញ្ហាទីបី គឺសហជីពខ្លះ ទោះបីជាគ្រប់ចំនួនក្នុងការបង្កើត និងចុះបញ្ជីរួចក៏ហើយក្តី តែបើយើងមកមើលពីការអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជាសហជីពវិញនោះ គឺនៅតែមានផលវិបាក ដល់ពួកគេជាពិសេសតំណាងសហជីពដែលមានកម្រិតវប្បធម៌ទាប។

ប្រការទាំងនេះ បានធ្វើឱ្យសហជីពកម្ពុជាមិនអាចដើរតួនាទីពេញលេញក្នុងការធ្វើជាតំណាងឱ្យកម្មករនិយោជិត ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ ស្របទៅតាមការកំណត់ដោយច្បាប់ ដែលមានជាធរមានឡើយ។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះការពិចារណារលើចំនួនសមាជិកក្នុងការបង្កើតសហជីពឡើងវិញ, ការចូលរួមពីស្ថាប័នចុះបញ្ជី និងការបង្កើតការបណ្តុះបណ្តាលដល់តំណាងសហជីពដែលមានកម្រិតវប្បធម៌ទាប។

សរុបជារួម បើទោះជារយៈពេលចុងក្រោយនេះ គិតត្រឹមឆ្នាំ២០២៣ ដល់ពាក់កណ្តាល២០២៤នេះ សិទ្ធិសេរីភាពរបស់សហជីពហាក់មានសញ្ញាវិជ្ជមានខ្លះដែលនាំឱ្យមានភាពប្រសើរឡើងក៏ដោយក្តី ប៉ុន្តែបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើនេះ នៅតែបន្តក្លាយជាបន្ទុក និងជាសម្ពាធទៅដល់សហជីពនៅកម្ពុជាក្នុងការអនុវត្តភាពជាអ្នកតំណាងរបស់ខ្លួនដដែល ប្រសិនបើគ្មានការពិភាក្សារកដំណោះស្រាយរួមទេ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សារួចមក យើងខ្ញុំដឹងកាន់តែច្បាស់ពីសារៈខាន់នៃតួនាទីរបស់សហជីព ក្នុងការតំណាងឱ្យកម្មករនិយោជិត សំដៅការពារផលប្រយោជន៍របស់កម្មករនិយោជិតនៅក្នុងសង្គមយើងបច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំទទួលបានព័ត៌មានចន្លោះខ្វះខាតមួយចំនួន ដែលមើលឃើញថាជាភាពអសកម្មនិង សំណូមពរឱ្យមានការកែប្រែ និងបំពេញបន្ថែម។ ដោយស្មារតីចង់ចូលរួមជាសំឡេងលើកកម្ពស់សិទ្ធិកម្មករនិងសហជីពប្រកបដោយបរិយាបន្ន និងជាផ្នែកមួយក្នុងការចូលរួមលើកទឹកចិត្តដល់កម្មករដែលជាផ្នែកមួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យមានការរីកចម្រើនផងនោះ យើងខ្ញុំសូមលើកនូវអនុសាសន៍មួយចំនួនដូចតទៅៈ

- គួរកាត់បន្ថយលក្ខខណ្ឌតម្រូវសមាជិកភាពអប្បបរមា ដែលមានកម្រិតខ្ពស់ហួសហេតុសម្រាប់បង្កើតសហជីព ។
- កែសម្រួលបទប្បញ្ញត្តិទាំងឡាយដែលមានលក្ខណៈទាមទារកំរិតចំណេះដឹងលើមូលដ្ឋានច្បាប់ខ្ពស់ ដែលធ្វើការសម្រេចចិត្ត របស់សហជីព និងកម្មករនិយោជិត រមែងនិងមិនសម្រេចដូចបំណង។
- សហជីពដែលមិនទាន់មានភាពជាតំណាងបំផុត ត្រូវរកសមាជិកឱ្យបានច្រើនដើម្បីធ្វើភាពជាអ្នកតំណាងបំផុត។
- ភាគីពាក់ព័ន្ធរួមមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរយកចិត្តទុកដាក់បន្ថែមលើសហជីព បន្តចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការយល់ដឹងនូវសិទ្ធិកម្មករនិងសហជីពតាមរយៈការបើកវគ្គបណ្តុះបណ្តាល ក៏ដូចជាការបើកកិច្ចប្រជុំជាមួយនឹងសហជីពក្នុងរយៈពេលមួយឆ្នាំបួនដង ដើម្បីបើកទូលាយដល់ការបញ្ចេញមតិ និងប្រាប់ពីផលពិបាកដែលរារាំងសេរីភាពរបស់សហជីព។
- ភាគីពាក់ព័ន្ធ រួមមានក្រសួងការងារជាអាទិ៍ គួរចាត់វិធានការ ឬបង្កើតជាគម្រោងកម្មវិធីផ្សព្វផ្សាយពីច្បាប់ការងារ តាមរយៈឌីជីថលក្រោមរូបភាពជាកម្មវិធីអប់រំ ឬបណ្តុះបណ្តាលផ្នែកច្បាប់ ជូនដល់សហជីព ឬកម្មករនិយោជិត។

ហើយចំណុចទាំងនេះក៏ត្រូវការ ការចូលរួមរបស់សហជីព និង កម្មករនិយោជិត ផ្ទាល់ផងដែរ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ឆ្នាំ១៩៤៨។

អនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពនៃ សមាគមនិងការការពារសិទ្ធិ នៃការបង្កើតសហគម,០៩ កក្កដា ១៩៤៨។

អនុសញ្ញាលេខ៩៨ ស្តីពីការអនុវត្តគោលការណ៍ស្តីអំពី សិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិការចរចាជាសមូហភាព, ០១ កក្កដា ១៩៤៩។

ច្បាប់ស្តីពីសហជីព, លេខ នស/រកម/០៥១៦/០០៧, ១៧ ឧសភា ២០១៦។

ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១, ១៣ មីនា ១៩៩៧។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព, លេខ នស/រកម/០១២០/០០១, ០៣ មករា ២០២០។

អនុសញ្ញាលេខ៨៧ ស្តីពី សេរីភាពនៃសមាគម និងការការពារសិទ្ធិ នៃការបង្កើតសមាមគម កម្ពុជាបានផ្តល់សច្ចាប័នថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩

អនុសញ្ញាលេខ៩៨ ការអនុវត្តគោលការណ៍ស្តីអំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព, កម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩

អនុក្រឹត្យលេខ១៦ អនក្រ/ប្រក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិ របបសន្តិសុខសង្គម

ប្រកាសលេខ៣១៨ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១

ប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជា សមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន

ប្រកាសលេខ០២១ ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការចុះបញ្ជិកា នៃអង្គការវិជ្ជាជីវៈ

សេចក្តីជូនដំណឹងលេខ១៦ សកបយ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នា២០០២ ស្តីពីការចុះបញ្ជិកានៃ អង្គការវិជ្ជាជីវៈ និងការបញ្ចប់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

## សៀវភៅ

នួន វាសនា និង Melisa Serrano. ការកសាងសហជីពនៅប្រទេសកម្ពុជា៖ កាលប្រវត្តិ ការប្រឈម និងយុទ្ធសាស្ត្រ .ប្រទេសសិង្ហបុរី៖ Friedrich-Ebert-Stiftung. ២០១០។

អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. "ក្រុមប្រឹក្សាអាជ្ញាកណ្តាល". កម្រងឯកសារស្តីពីស្ថាប័នរបស់ ម.ស.ម.ក. លេខពិសេស ធ្នូ ២០១៣។

អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. "ច្បាប់ស្តីពីសហជីព". កម្រងឯកសារស្តីពីការចាត់ចំណាត់ថ្នាក់របស់ ម.ស.ម.ក. លេខ ១០. សីហា ២០១៦។

ហ៊ីរ៉ូអាគី វ៉ាតាណាបេ, "កំណែទម្រង់ទីផ្សារការងារ និងការចុះខ្សោយនៃសហជីពការងារក្នុងប្រទេសជប៉ុន" , ជប៉ុន៖ អត្ថបទស្រាវជ្រាវរបស់សាស្ត្រាចារ្យនៃសាកលវិទ្យាល័យរីស៊ុមេកាន, ខែ កញ្ញា ឆ្នាំ ២០២៣ https://www.jil.go.jp/institute/zassi/backnumber/2023/09/pdf/004-017.pdf (បានចូលមើលចុងក្រោយ ០១ សីហា ២០២៤)

អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. "ការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា". គម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន របាយការណ៍ប្រចាំឆ្នាំទី៤ (ខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០)។

ការកសាងសហជីពនៅកម្ពុជា ប្រវត្តិ បញ្ហាប្រឈម យុទ្ធសាស្ត្រ នួន សាសនា និងម៉ាលីសា សេវ៉ាណូ

សៀវភៅសិក្សាស្តីពីសហជីព ឧបត្ថម្ភបោះពុម្ពដោយ គម្រោងអប់រំសហជីពនៃអង្គការពល កម្មអន្តរជាតិ(ILO-WEP)

## គេហទំព័រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, www.mlvt.gov.kh

ក្រុមប្រឹក្សាអាជ្ញាកណ្តាល, www.arbitrationcouncil.org

យ៉ាសូអេដា, នីស៊ីម៉ូរ៉ា, នីតិការងារ(ជប៉ុន៖ រោងពុម្ពយីហ៊ីកាកី, បោះពុម្ពលើកទី១០, ២០១០) ២៦៨-២៦៩។

អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍. "សហជីព". ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

https://opendevelopmentcambodia.net/km/topics/unions/#ref-73548-2 (បានចូលមើលចុងក្រោយ ២០ មេសា ២០២៣)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល, "អ្វីទៅជាភាពខុសគ្នារវាងវិវាទអំពីសិទ្ធិ និងវិវាទអំពីផលប្រយោជន៍?", ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០១៩, https://www.arbitrationcouncil.org/right-vs-interests-disputes-whats-the-difference/ (ចូលមើលចុងក្រោយ ២០ កក្កដា ២០២៤)។

ជួប នរក្សា, "ទិវាពលកម្មអន្តរជាតិ៖ សហជីពទាមទាររដ្ឋាភិបាលតម្លើងប្រាក់ខែកម្មករឱ្យបាន២៥០ដុល្លារក្នុងមួយខែ", វិទ្យុស្ថានបារាំងអន្តរជាតិ, ០១ ឧសភា ២០២៣, https://rfi.my/9RCx (បានចូលមើលចុងក្រោយ ៣០ មិថុនា ឆ្នាំ២០២៤)។

Fresh New, "រដ្ឋមន្ត្រីក្រសួងការងារ៖ សហជីពសឹងតែ១០០% អះអាងថាខ្លួនឯករាជ្យ ប៉ុន្តែខ្លះបែរជាដើរធ្វើសកម្មភាពផ្ទុយនឹងច្បាប់",០១ឧសភា២០១៧,
https://freshnewsasia.com/index.php/en/localnews/53727-2017-05-01-07-22-15.html (បានចូលមើលចុងក្រោយ ២៩ កក្កដា ២០២៤)

ការវិភាគផ្នែកសិទ្ធិមនុស្ស នៃសេចក្តីព្រាងច្បាប់ស្តីពីសហជីព" រៀបចំឡើងដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា
https://cambodia.ohchr.org/sites/default/files/TUL_Analysis-Kh.pdf

ទិដ្ឋភាពទូទៅនៃការស្ទង់មតិមូលដ្ឋានសហជីពការងារឆ្នាំ ២០២៣ របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពជប៉ុន 厚生労働省「令和５年労働組合基礎調査の概況」3 頁
https://www.mhlw.go.jp/toukei/itiran/roudou/roushi/kiso/23/dl/gaikyou.pdf

Japan International labor foundation , ឯកសារសរុបទិន្នន័យរបស់សហព័ន្ធការងារវៀតណាម(VGCL)
（公益財団法人国際労働財団、ベトナム労働総同盟の合計データのレポート(VGCL)）
https://www.jilaf.or.jp/nc_view/nc_view-1361/

មេដឹកនាំសហជីព៖ ការបង្កើតសហជីពឯករាជ្យកំពុងស្ថិតក្រោមការរឹតត្បិត និងប្រឈមការរើសអើងកាន់តែខ្លាំងhttps://khmer.voanews.com/a/union-leaders-say-after-the-amendment-of-labor-laws-the-formation-of-independent-unions-is-under-restriction-and-faces-discrimination/7160051.html(បានចូលមើលចុងក្រោយ ២៤ មិថុនា ២០២៤)។

ការលើកឡើងរបស់លោក អាត់ ធន់ ជាប្រធានសហភាពការងារកម្ពុជ(CambodiaLabourConfederation) បានផ្តល់កិច្ចសម្ភាសដល់សិក្ខាកាម Newsroom Cambodia អំពីបញ្ហាប្រឈមរបស់តំណាងសហជីពនៅក្នុងកន្លែងការងារ ថ្ងៃទី៦ ខែ វិច្ឆិកា ឆ្នាំ២០២២,
https://newsroomcambodia.com/news/2022/11/16/qa%E1%9F%96-%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%94%E1%9E%84%E1%9F%92%E1%9E%80%E1%9E%BE%E1%9E%8F%E1%9E%9F%E1%9E%A0%E1%9E%87%E1%9E%B8%E1%9E%96%E1%9E%93%E1%9F%85/(បានចូលមើលចុងក្រោយ ២៤ មិថុនា ២០២៤)។

ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០២៣

https://www.youtube.com/live/RniZDM1s72A?si=5JYOrqvKinJ1mmm8(បានចូលមើលចុងក្រោយ ២៩ សីហា ២០២៤)។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ព្រះរាជក្រម

នស/រកម/០៥១៦/០០៧

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសហជីព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៦០/០០២/២០១៦កបធ.ច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្ដីពី

# សហជីព

ការកាត់ប្រាក់ឈ្នួលសាមីជនសម្រាប់បង់ភាគទានសហជីព ។ គ្មានបុគ្គលណាអាចរារាំងដល់សិទ្ធិរបស់កម្មករ និយោជិតក្នុងការចូលរួម ឬការចាកចេញពីសហជីពណាមួយនោះឡើយ ។

## មាត្រា ៨.- សេរីភាពក្នុងការចូលរួមនៅក្នុងការដឹកនាំ និងការគ្រប់គ្រង

អនុលោមតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ សមាជិកនៃសហជីព ឬសមាជិកនៃសមាគមនិយោជកទាំងអស់ អាចចូលរួមក្នុងការងារដឹកនាំ ការងារគ្រប់គ្រង និងការងាររដ្ឋបាលរបស់សហជីព ឬសមាគមនិយោជកទាំងនោះ ។ លក្ខន្តិកៈរបស់សហជីព ឬសមាគមនិយោជក អាចបន្ថយលក្ខខណ្ឌសម្រាប់ការចូលរួមរបស់អ្នកចូលនិវត្តន៍នៅក្នុងមុខងារទាំងនេះ ។

## មាត្រា ៩.- សិទ្ធិរបស់សហជីព និងសមាគមនិយោជក

ក្រុមប្រឹក្សាជាតិសហជីព សហជីព និងសមាគមនិយោជក មានសិទ្ធិដូចតទៅ ៖

- តាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរដ្ឋបាល រៀបចំការប្រព្រឹត្តទៅ និងកម្មវិធីការងាររបស់ខ្លួន ដោយមិនឲ្យផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ បទប្បញ្ញត្តិ និងច្បាប់ជាធរមាន
- បោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី ។

## មាត្រា ១០.- រចនាសម្ព័ន្ធសហជីព ឬសមាគមនិយោជក និងសម្ព័ន្ធភាពរវាងសហជីព ឬសមាគមនិយោជក

សហជីពមានរចនាសម្ព័ន្ធ ៣ (បី) ថ្នាក់ដូចតទៅ ៖

១-សហជីពមូលដ្ឋានមួយ ត្រូវបានបង្កើតឡើងដោយកម្មករ និយោជិតនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមូលដ្ឋាននោះចំនួនយ៉ាងតិច ១០ (ដប់) នាក់ ។

២-សហព័ន្ធសហជីពមួយ ត្រូវបានបង្កើតឡើងដោយសហជីពមូលដ្ឋានដែលមានបញ្ជិកាចំនួនយ៉ាងតិច ៧ (ប្រាំពីរ) ។

៣- សហភាពសហជីព ឬសម្ព័ន្ធសហព័ន្ធសហជីពមួយ ត្រូវបានបង្កើតឡើងដោយសហព័ន្ធសហជីពដែលមានបញ្ជិកាចំនួនយ៉ាងតិច ៥ (ប្រាំ) ។

សមាគមនិយោជកមានរចនាសម្ព័ន្ធ ២ (ពីរ) ថ្នាក់ដូចតទៅ ៖

១- សមាគមនិយោជកមួយ ត្រូវបានបង្កើតឡើងដោយសហគ្រាស ឬគ្រឹះស្ថានចំនួនយ៉ាងតិច ៩ (ប្រាំបួន) ។

២- សហព័ន្ធនិយោជក ត្រូវបានបង្កើតឡើងដោយសមាគមនិយោជកដែលមានបញ្ជិកាចំនួនយ៉ាងតិច ៦ (ប្រាំមួយ) ។

សហជីព ឬសមាគមនិយោជក អាចពិគ្រោះយោបល់គ្នាបានដោយសេរីអំពីការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការលើកតម្កើងវិជ្ជាជីវៈ និងការការពារផលប្រយោជន៍ផ្នែកស្មារតី និងសម្ភារៈ ។

សហជីពអាចចងសម្ព័ន្ធភាពជាមួយសហជីពផ្សេងទៀតជាលក្ខណជាតិ និងអន្តរជាតិ ។

សមាគមនិយោជកក៏មានសិទ្ធិដូចគ្នានេះដែរ ។

**មាត្រា ១៩.- ការលុបបញ្ជិកា**

តុលាការការងារមានសមត្ថកិច្ចក្នុងការសម្រេចលុបបញ្ជិកា ។ ក្រសួងទទួលបន្ទុកវិស័យការងារអាចប្តឹងទៅតុលាការការងារដើម្បីស្នើសុំលុបបញ្ជិកា ។

បញ្ជិកាត្រូវបានលុបដោយស្វ័យប្រវត្តិក្នុងករណីដែលសហជីព ឬសមាគមនិយោជកត្រូវបានរំលាយ ។

**មាត្រា ២០ .- លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពនៅក្នុងសហគ្រាស ឬគ្រឹះស្ថាន**

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព ដែលជាពលរដ្ឋខ្មែរត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

ក- មានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី) ឆ្នាំ

ខ-ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់

គ- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមានកម្រិតវប្បធម៌យ៉ាងហោចណាស់ចេះអាន ចេះសរសេរអក្សរខ្មែរ

ឃ- ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ។



អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព ដែលជាជនបរទេសត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

ក-មានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី) ឆ្នាំ

ខ-ចេះអាន និងចេះសរសេរអក្សរខ្មែរ

គ-បាន និងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ២ (ពីរ) ឆ្នាំ

ឃ-ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

ង-មានសិទ្ធិស្នាក់នៅ និងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ ក្រសួងទទួលបន្ទុកវិស័យការងារអាចស្នើសុំព័ត៌មានបន្ថែម ។

## មាត្រា ៥៨.- សិទ្ធិ និងករណីយកិច្ចរបស់សហជីពដែលមានភាពជាតំណាងបំផុត

បន្ថែមទៅលើសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ សហជីពដែលមានភាពជាតំណាងបំផុតមានករណីយកិច្ចដូចខាងក្រោម ៖

- ចរចាដោយភាពស្មោះត្រង់ជាមួយនិយោជកក្នុងគោលបំណងឲ្យមានការព្រមព្រៀងជាសមូហភាពទៅលើអនុសញ្ញារួមដែលផ្តោតទៅលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗទៀត
- ធ្វើជាតំណាងដោយភាពស្មោះត្រង់ឲ្យកម្មករ និយោជិតដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្តឹងតវ៉ាមិនសុខចិត្តដែលកើតចេញពីអនុសញ្ញារួម
- មិនត្រូវរើសអើងនៅក្នុងពេលទទួលយកសមាជិកថ្មី
- បែងចែកអាសនៈនៅក្នុងយន្តការមួយចំនួនដែលបានកំណត់ក្នុងច្បាប់ស្តីពីការងារ ។

## មាត្រា ៥៩.- សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុត

សហជីពដែលមានសមាជិកភាគតិចទាំងឡាយនៅក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពមានភាពជាតំណាងបំផុតត្រូវបានបញ្ជាក់រួច ហើយដែលកំពុងស្ថិតនៅក្នុងសុពលភាពត្រូវបានហាមឃាត់លើការទាមទារសិទ្ធិចរចាអនុសញ្ញារួម និងការទាមទារសិទ្ធិ ឬអត្ថប្រយោជន៍ផ្សេងៗដែល



លើសពីអត្ថប្រយោជន៍ចែងនៅក្នុងច្បាប់ បទបញ្ជា អនុសញ្ញារួមដែលកំពុងមានសុពលភាព ឬវិធានការងារផ្ទៃក្នុងទាំងឡាយ ។ សិទ្ធិ និងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចរួមមាន ៖

ក-ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ

ខ-ការផ្តល់ប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន

គ-ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទបុគ្គល

ឃ-ការចូលរួមនៅក្នុងយន្តការកិច្ចសហការនៅកន្លែងការងារដែលប្រព្រឹត្តទៅជាប្រចាំ

ង-ការចូលរួមប្រឹក្សាយោបល់នៅក្នុងយន្តការទីផ្សារការងារ

ច-ការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន

ឆ- ការរៀបចំបង្កើតនូវសហករណ៍ដែលអាចជាហាងលក់ដូរតវ៉ាន់ អាហារដ្ឋាន ឬការថែរក្សាសុខភាព ។ល។ សម្រាប់សម្រួលដល់ជីវភាពរស់នៅរបស់សមាជិកខ្លួន

ជ- តួនាទីផ្នែករដ្ឋបាលនៅក្នុងការផ្តល់ឲ្យនូវអត្ថប្រយោជន៍ដល់សមាជិករបស់ខ្លួនពេលគ្មានការងារធ្វើ ។

សហជីពមានភាពជាតំណាងបំផុតក៏អាចអនុវត្តតួនាទីដែលមានកំណត់ក្នុងចំណុច "ក" ដល់ចំណុច "ជ" ខាងលើនេះដែរ ។